សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# បណ្តឹងទាស់ក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៧


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ កញ្ញា **ឃិន សម្ផស្ស** | លោក **ឆឹង ស៊ីនៀង** |


| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាន់ទី ១៧ | ឆ្នាំសរសេរសារណា | ២០១៧ |

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ចិន សម្ផស្ស** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៣-២០១៧។

## សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនៈ

- លោកឪពុក **សៅ ចិន** និងអ្នកម្តាយ **ឈិន នាង** ដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងផ្តល់កម្លាំងចិត្ត និងថវិកា ទំនុកបំរុង គ្រប់បែបយ៉ាង អោយរូបនាងខ្ញុំក្លាយជាពលរដ្ឋដ៏ល្អ និងមានលទ្ធភាពទទួលបានការអប់រំ រហូត បានបញ្ចប់ថ្នាក់ឧត្តមសិក្សា ប្រកបដោយភាពជោគជ័យ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា និងការិយាល័យស្រាវជ្រាវ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន ណែនាំយ៉ាងយកចិត្តទុកដាក់ និងបានផ្តល់ចំណេះដឹងដ៏មានតម្លៃ និងបានរៀបចំនូវកម្មវិធីសិក្សាដ៏មានអត្ថប្រយោជន៍ និងបង្កភាពងាយស្រួលដល់រូបនាងខ្ញុំក្នុងការសិក្សា។
- លោកសាស្ត្រាចារ្យ **នឹម ស៊ីនៀង** ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយទាំងកម្លាំងកាយចិត្តពេលវេលាដ៏មានតម្លៃជួយពន្យល់ណែនាំ និងផ្តល់វិធីសាស្ត្រល្អៗ
- សូមថ្លែងអំណរគុណចំពោះមិត្តរួមថ្នាក់និងបងប្អូនទាំងអស់ដែលបានជួយផ្តល់គំនិតយោបល់ និងជួយលើកទឹកចិត្តដល់រូបនាងខ្ញុំ។

គុណូបការៈ ដ៏ថ្លៃថ្លាទាំងនេះធ្វើឱ្យនាងខ្ញុំមិនអាចបំភ្លេចបានឡើយ ករណីកិច្ចជាកតវេទី យើងខ្ញុំគ្មានអ្វីក្រៅពីប្រសិទ្ធពរជ័យ និងបួងសួងសូមលោកអ្នកទាំងអស់គ្នាជួបតែគុណបុណ្យព្រះរតនត្រ័យដែលជាវត្ថុស័ក្តិសិទ្ធ ក្នុងលោកមាន ពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ ជាទីពឹងទីរលឹកគ្រប់ពេលវេលា និងគ្រប់ៗជាតិកុំបីវិបល្លាសក្លាយទៅជាបការៈដទៃឡើយ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុត អំពីនាងខ្ញុំ **ចិន សម្ផស្ស**។

# អារម្ភកថា

នាងខ្ញុំជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ ក្រោយពីបានបញ្ចប់ការសិក្សាអស់រយៈពេល៤ឆ្នាំមក នាងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើន ដែលចំណេះដឹងទាំងនេះបានមកពី ការបង្ហាត់បង្ហាញយ៉ាងយកចិត្តទុកដាក់ពីសំណាក់សាស្ត្រាចារ្យល្បីៗ មានបទពិសោធន៍ខ្ពស់ទាំងក្នុងការបង្រៀន និងការប្រតិបត្តិផ្នែកវិជ្ជាជីវៈច្បាប់។ មានសេចក្ដីសោមនស្ស រីករាយជាទីបំផុត ដោយមានឱកាសចងក្រងនូវស្នាដៃនេះ ដើម្បីទទួលបាននូវចំណេះដឹងបន្ថែម និងបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

សារណានេះ នាងខ្ញុំបានពិពណ៌នាអំពីនីតិវិធី និងដំណើរការបណ្ដឹងទាស់នៅក្នុងរឿងក្ដីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្ដីដែលបានរៀបរាប់ក្នុងសារណានេះបានដកស្រង់ចេញពីប្រភពច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសនោះគឺក្រមនីតិវិធីព្រហ្មទណ្ឌ និងឯកសារពាក់ព័ន្ធនឹងការអនុវត្តជាក់ស្ដែងនាពេលបច្ចុប្បន្នរបស់បណ្ដឹងទាស់។

នាងខ្ញុំសង្ឃឹមថាសារណានេះ និងមានប្រយោជន៍ចំពោះនិស្សិតជំនាន់ក្រោយ រួមទាំង ប្រជាពលរដ្ឋក្នុងការស្រាវជ្រាវអំពី ដំណើរការប្ដឹងទាស់ នៅស្ថាប័នតុលាការ។

នាងខ្ញុំដឹងថា វាពិតជាមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយត្រង់ កន្លែងណាមួយជាមិនខាន។ តែនាងខ្ញុំសុមស្វាគមន៍រាល់ការរិះគន់ និងកែលំអរ ដើម្បីឱ្យនាងខ្ញុំមានគំនិតកាន់តែរីកចំរើនបន្ថែមទៀតដោយក្នុងន័យនៃការស្ថាបនា ស្នាដៃឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

ជាចុងក្រោយនេះ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះមិត្តអ្នកអានដែលបានចំណាយពេលវេលាក្នុងការអានសៀវភៅនេះ ហើយសូមជូនពរ ឯកឧត្ដម លោក លោកស្រី និងសាស្ត្រាចារ្យដែលបានជួយណែនាំ អោយជួបតែសេចក្ដីសុខគ្រប់ប្រការ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** .................................................... ០១

**ជំពូកទី១៖បណ្តឹងទាស់ ទៅនឹងសាលក្រមតុលាការ**.............. ............ ០៥

១.១និយមន័យនៃបណ្តឹងទាស់.................................................... ០៥

១.២ ទម្រង់នៃបណ្តឹងទាស់ .................................................... ០៦

១.៣ ទីកន្លែងសម្រាប់ធ្វើបណ្តឹងទាស់.................................................... ០៦

១.៤ ភាគីនៃបណ្តឹងទាស់ .................................................... ០៦

១.៤.១ ពិរុទ្ធជន.................................................... ០៧

១.៤.១.១ សញ្ញាណទូទៅនៃពិរុទ្ធជន .................................................... ០៧

១.៤.១.២ សិទ្ធ និងភាតព្វកិច្ចរបស់ពិរុទ្ធជន.... .................................................... ០៧

១.៤.១.៣ បណ្តឹងទាស់ធ្វើឡើងដោយពិរុទ្ធជន .................................................... ០៧

១.៤.២ ដើមបណ្តឹងរដ្ឋប្បវេណី.......... .................................................... ០៨

១.៤.២.១ សញ្ញាណទូទៅនៃដើមបណ្តឹងរដ្ឋប្បវេណី. .................................................... ០៨

១.៤.២.២ អាជ្ញាយុកាលនៃបណ្តឹង.................................................... ១០

១.៤.២.៣ សិទ្ធ និងភាតព្វកិច្ចដើមបណ្តឹងរដ្ឋប្បវេណី .................................................... ១០

១.៤.២.៤ ទំនាក់ទំនងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី................ ១០

១.៤.៣ ព្រះរាជអាជ្ញា.................................................... ១១

១.៤.៣.១ សញ្ញាណទូទៅនៃព្រះរាជអាជ្ញា .................................................... ១១

១.៤.៣.២ សិទ្ធ និងការព្វកិច្ចរបស់ព្រះរាជអាជ្ញា.................................................... ១១

១.៤.៣.៣ កម្មវត្ថុនៃបណ្តឹងអាជ្ញា .................................................... ១១

១.៤.៣.៤ ការចាប់ផ្ដើមនៃបណ្ដឹងអាជ្ញាដោយអយ្យការ......................................... ១២

១.៤.៣.៥ ការផុតរលត់នៃបណ្ដឹងអាជ្ញា ................................................................. ១២

១.៥. រយៈពេលសម្រាប់ធ្វើការប្ដឹងទាស់...........................................................១២

១.៥.១ រយៈពេលសម្រាប់ធ្វើការប្ដឹងទាស់របស់ពិរុទ្ធជន ....................................១២

១.៥.២ រយៈពេលសម្រាប់ធ្វើការប្ដឹងទាស់ដើមបណ្ដឹងរដ្ឋប្បវេណី................... ១៣

១.៦. អានុភាពនៃបណ្ដឹងទាស់.................................................................... ១៣

១.៧ សាលក្រមសម្រេចលើបណ្ដឹងទាស់ ............................................................... ១៣

ជំពូកទី២៖ បណ្ដឹងឧទ្ធរណ៍ទៅនឹងសាលក្រមរបស់តុលាការ........................ ១៤

២.១.និយមន័យ បណ្ដឹងឧទ្ធរណ៍.................................................................. ១៥

២.២ទីកន្លែងសម្រាប់ប្ដឹងឧទ្ធរណ៍................................................................ ១៥

២.៣ ទម្រង់នៃបណ្ដឹងឧទ្ធរណ៍. .................................................................... ១៥

២.៣.១ ទម្រង់នៃបណ្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ..............................................១៥

២.៣.២ ទម្រង់នៃបណ្ដឹងឧទ្ធរណ៍ដើមបណ្ដឹងរដ្ឋប្បវេណី...................................១៦

២.៣.៣ ទម្រង់នៃបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ........................................១៦

២.៣.៤ ទម្រង់នៃបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា................................ ១៧

២.៤ ភាគីនៃបណ្ដឹងឧទ្ធរណ៍.......................................................................... ១៧

២.៤.១ ពិរុទ្ធជន ............................................................................................. ១៧

២.៤.២ *ដើមបណ្ដឹងរដ្ឋប្បវេណី* ........................................................................១៨

២.៤.៣ ព្រះរាជអាជ្ញា..... ................................................................................១៨

២.៤.៤ អគ្គព្រះរាជអាជ្ញា..................................................................................១៨

២.៥ រយៈពេលប្តឹងឧទ្ធរណ៍.................................................................................................. ១៩

២.៥.១ រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន .....................................................១៩

២.៥.២ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី...................១៩

២.៥.៣ ព្រះរាជអាជ្ញា ........................................................................................១៩

២.៥.៤ អគ្គព្រះរាជអាជ្ញា....................................................................................២០

២.៦.អានុភាពនៃបណ្តឹងឧទ្ធរណ៍............................................................................២០

២.៦.១ អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម .............................. ២០

២.៦.២ អានុភាពនៃបណ្តឹងឧទ្ធរណ៍លើជនជាប់ចោទ.......................................... ២០

២.៦.៣ អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា........................................ ២១

២.៦.៤ អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា .................................. ២១

២.៦.៥អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ............................ ២១

២.៦.៦ បណ្តឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន ............................................ ២១

២.៦.៧ ការជំនុំជម្រះសាលក្រម.............................................................................២២

២.៦.៨ដីកាបង្គាប់ឱ្យឃុំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួនចេញដោយសាលាឧទ្ធរណ៍ ........២២

២.៧.អានុភាពនៃសាលដីកា.....................................................................................២២

២.៧.១ អានុភាពនៃការអនុវត្ត .............................................................................២២

២.៨ បណ្តឹងទាស់ទៅនឹងសាលដីកាចេញដោយកំបាំងមុខ.................................. ២៣

២.៨.១ ទម្រង់នៃបណ្តឹងទាស់..................................................................... ២៣

២.៨.១.១ ទម្រង់នៃបណ្តឹងទាស់របស់ពិរុទ្ធជន. ..............................................២៣

២.៨.១.២ ទម្រង់នៃបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី. .............................. ២៤

២.៨.២ ភាគីដែលអាចប្តឹងទាស់...........................................................................២៤

២.៨.៣ រយៈពេលនៃបណ្ដឹងទាស់............................................................ ២៤

២.៨.៣.១ រយៈពេលនៃបណ្ដឹងទាស់របស់ពិរុទ្ធជន ............................................ ២៤

២.៨.៣.២ រយៈពេលនៃបណ្ដឹងទាស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ............................ ២៥

២.៨.៤ បណ្ដឹងទាស់ចំពោះសេចក្ដីសម្រេចព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី .............. ២៥

២.៨.៥ សាលដីកាសម្រេចលើបណ្ដឹងទាស់ ................................................ ២៥

២.៩ បណ្ដឹងសារទុក្ខ ........................................................................ ២៦

២.៩.១ បុគ្គលដែលអាចប្ដឹងសាទុក្ខ............................................................ ២៦

២.៩.២ មូលហេតុនៃបណ្ដឹងសាទុក្ខ............................................................ ២៦

២.៩.៣ ទម្រង់នៃការប្រកាសបណ្ដឹងសាទុក្ខ .................................................. ២៧

២.៩.៣.១ ទម្រង់នៃបណ្ដឹងសាទុក្ខរបស់ពិរុទ្ធជន ............................................ ២៧

២.៩.៣.២ ទម្រង់នៃបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី.............................. ២៧

២.៩.៣.៣ ការចុះហត្ថលេខាលើបណ្ដឹងសាទុក្ខ................................................. ២៧

២.៩.៤ រយៈពេលដើម្បីធ្វើបណ្ដឹងសាទុក្ខ.................................................... ២៧

២.៩.៥ ការបញ្ជូនសំណុំរឿងទៅតុលាការកំពូល ............................................ ២៨

២.៩.៦ ករណីបង្វិលពីតុលាការកំពូល ........................................................ ២៨

សេចក្ដីសន្និដ្ឋាន.......................................................................... ២៩

អនុសាសន៍.................................................................................. ៣២

ឯកសារយោង

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក មិនថាកាន់របបនយោបាយអ្វីនោះទេ យើងតែងតែសង្កេតឃើញមាន ការបែងចែកអំណាចដាច់ៗដោយឡែកពីគ្នាជាក់ស្តែង យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា មាត្រា ៥១ថ្មី វាក្យខណ្ឌទី៤ បានចែងថា អំណាចត្រូវបានបែងចែកដាច់ៗពីគ្នារវាង អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ មិនតែប៉ុណ្ណោះ មាត្រា១២៨ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជាបានចែងថាអំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងអំណាចសិទ្ធសេរីភាព របស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្រប ដណ្តប់ទៅលើរឿងក្តី ទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាម ប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ហើយមានតែចៅក្រមទេដែលមានសិទ្ធជំនុំជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចទាំងនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីជម្រៅ ដូងចិត្ត និងសម្បជញ្ញៈ របស់ខ្លួន។

ការបង្កើតប្រព័ន្ធតុលាការគឺជាមធ្យោបាយតែមួយគត់ដើម្បីការពារសិទ្ធមនុស្ស។ នៅប្រទេសកម្ពុជាយើងប្រព័ន្ធតុលាការមានការផ្លាស់ប្តូរជាញឹកញាប់។ ប៉ុន្តែចាប់ពីឆ្នាំ ១៩៧៩ ដល់១៩៨៥ តុលាការនៅកម្ពុជាមានតែមួយថ្នាក់ប៉ុណ្ណោះ ហៅថា តុលាការខេត្ត-ក្រុងដែលជាតុលាការជម្រះក្តីជាន់ដំបូងឬជំនុំជម្រះលើកទីមួយ និងជាលើកចុងក្រោយបង្អស់ដែលមានន័យថាគ្មានការទុករយៈពេលប្តឹងឧទ្ធរណ៍ដូច ប្រព័ន្ធនីតិវិធីតុលាការនាពេលបច្ចុប្បន្ននេះទេ។ នៅសម័យកាលនោះក្រសួងយុត្តិធម៌ ជាអ្នកដែលមានសមត្ថកិច្ចត្រួតពិនិត្យមើលឡើងវិញទៅលើសេចក្តីសម្រេចរបស់ តុលាការខេត្ត-ក្រុង ហើយអាចមានសេចក្តីសម្រេចចុងក្រោយបំផុតដោយក្រុមប្រឹក្សារដ្ឋ។ ក្នុងករណីមានសេចក្តីស្នើពីក្រសួងយុត្តិធម៌។ ប្រសិនបើក្រុមប្រឹក្សារដ្ឋ យល់ឃើញថាសំណើរសុំបដិសេធសាលក្រមរបស់ក្រសួងយុត្តិធម៌ជាការត្រឹមត្រូវនោះ ក្រុមប្រឹក្សារដ្ឋចាំបាច់ត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត-ក្រុងជំនុំជម្រះឡើងវិញ។ ម្យ៉ាងទៀតនៅសម័យនោះក្រុមប្រឹក្សារដ្ឋមានអំណាច អនុវត្តសិទ្ធអយ្យការផងដែរក្នុងនីតិវិធីបណ្តឹងព្រហ្មទណ្ឌ។ ទម្រង់បែបនេះហាក់ដូចជាមិនដាច់ស្រឡះសោះរវាងអំណាចពិតប្រាកដរបស់អាជ្ញាធរនីមួយៗ។

ពេលនេះយើងក្រឡេកមកមើលប្រព័ន្ធតុលាការបច្ចុប្បន្នវិញម្តង។

សព្វថ្ងៃសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា មានពីរថ្នាក់ធំៗគឺ ថ្នាក់ទីមួយមាន សាលាដំបូងរាជធានី-ខេត្ត និងតុលាការយោធា រីឯថ្នាក់ទីពីរ មានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាដំបូងរាជធានី-ខេត្តមានសមត្ថកិច្ចត្រឹមភូមិសាស្ត្រដែលខ្លួន

កំពុងតាំងនៅប៉ុណ្ណោះ ពោលគឺមិនមានវិសាលភាពធំទូលាយដូច សាលាឧទ្ធរណ៍ និង តុលាការកំពូលនោះទេ ព្រោះសាលាជម្រះក្តីនេះ មានទីតាំងតែមួយប៉ុណ្ណោះនៅ រាជធានីភ្នំពេញ។ តុលាការកម្ពុជាបច្ចុប្បន្នផ្ទុយយ៉ាងស្រឡះអំពី តុលាការសម័យមុន ដោយតុលាការនៅសម័យមុន មានតែការជម្រះក្តីនៅតុលាការជាន់ដំបូងតែមួយដោយ មិនមានទុកការឱកាសឱ្យភាគីណាមួយនៃរឿងក្តីអាចមានការតវ៉ាទៅលើការសម្រេចនោះ បានឡើយបើទោះបីជាខ្លួនមានការពេញចិត្តឬមិនពេញចិត្តយ៉ាងក៏ដោយ។

ប៉ុន្តែតុលាការបច្ចុប្បន្ននេះវិញ បានផ្តល់សិទ្ធយ៉ាងពេញលេញអោយដល់ជនទាំង ឡាយណា ដែលមិនពេញចិត្តនឹង សេចក្តីសម្រេចណាមួយរបស់តុលាការនោះទេគឺ ទុក ឱកាសដល់គ្រប់ភាគីទាំងអស់នៃរឿងក្តីអាចធ្វើការប្តឹងទាស់នឹងសេចក្តីសម្រេចនោះបាន មិនថា សេចក្តីសម្រេច របស់ តុលាការជាន់ទាប ឬសាលាជម្រះក្តីជាន់ខ្ពស់នោះទេ។ ការប្តឹងទាស់នេះទៀតសោតគ្រប់ភាគីទាំងអស់នៃរឿងក្តីអាចធ្វើការប្តឹងទាស់ បានទាំង សាលក្រមកំបាំងមុខនិងសាលក្រមចំពោះមុខ។ ដោយនៅដំណាក់កាល តុលាការជាន់ ដំបូង ភាគីអាចធ្វើការប្តឹងទាស់នឹងសាលក្រមនោះបាន ប្រសិនបើមានការសម្រេចក្តី កំបាំងមុខដើម្បីឱ្យខ្លួនមានសិទ្ធក្នុងការប្តឹងទាស់បន្តទៀត ព្រោះការចេញសាលក្រម កំបាំងមុខបានបិទផ្លូវតវ៉ាដល់គ្រប់ភាគីទាំងអស់មិនឱ្យមានសិទ្ធក្នុងការ ប្តឹងឧទ្ធរណ៍បន្ត ទៀតឡើយ។ បន្ទាប់ពីទទួលបាននូវសាលក្រមចំពោះមុខ នៅសាលាដំបូងរួចហើយ កាលណាភាគីណាមួយនៃរឿងក្តីមិនសុខចិត្តទៅនឹងការសម្រេចណាមួយរបស់តុលាការ ភាគីទាំងនោះមានសិទ្ធក្នុងការប្តឹងទាស់នឹងសាលក្រមរបស់តុលាការនោះទៀត ដោយ អាចធ្វើទៅបានតាមរយៈ បណ្តឹងឧទ្ធរណ៍ និងអាចបន្តធ្វើការប្តឹងទាស់នេះរហូតដល់ តុលាការកំពូលទៀតតាមរយៈបណ្តឹងសារទុក្ខប្រសិនបើភាគីណាមួយនៅតែមិនសុខចិត្ត ចំពោះសេចក្តីសម្រេចណាមួយរបស់តុលាការ។ ការប្តឹងទាស់នេះភាគីទាំងអស់អាចប្តឹង ទាស់ ទៅលើ ចំណុចណាមួយ ឬអាចជាចំណុចទាំងអស់នៅក្នុងសេចក្តីសម្រេចនោះ។ ដោយនៅក្នុងដំណាក់កាលនីមួយៗនៃការប្តឹងទាស់នឹងសេចក្តីសម្រេចនេះ ដំណើរការ ទៅតាមនីតិវិធីផ្សេងៗពីគ្នា។ នាពេលបច្ចុប្បន្ននេះស្ថាប័នតុលាការកម្ពុជាជម្រះក្តី ទៅលើ សំណុំរឿងរដ្ឋប្បវេណីផងនិងព្រហ្មទណ្ឌផង។ ប៉ុន្តែនៅក្នុងសារណានេះនាងខ្ញុំសូមលើក យកមកបង្ហាញតែអំពី **បណ្តឹងទាស់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ** ប៉ុណ្ណោះ ព្រោះថា បច្ចុប្បន្នការយល់ដឹងពីនីតិវិធីព្រហ្មទណ្ឌ របស់ប្រជាពលរដ្ឋខ្មែរនៅមានកំរិតនៅឡើយ ដែលនេះជាមូលហេតុដែលធ្វើឱ្យពួកគាត់ងាយស្រួល និងជួបប្រទះការបាត់បង់នូវសិទ្ធ ហើយមិនដឹងទាល់តែសោះថាត្រូវធ្វើអ្វីខ្លះ នៅពេលដែលខ្លួនគាត់ត្រូវតវ៉ាក្តីនៅតុលាការ ព្រហ្មទណ្ឌ និងដើម្បីទុកជាឯកសារសំរាប់សិក្សាស្រាវជ្រាវ អាចជាមូលដ្ឋានគ្រឹះសំរាប់

ធ្វើការសិក្សាស្វែងយល់អំពី នីតិវិធីច្បាប់ ដែលអនុវត្តនៅក្នុង ព្រះរាជាណាចក្រកម្ពុជា យើងនាពេលបច្ចុប្បន្ន។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

មុននឹងដល់ការបកស្រាយប្រធានបទអោយល្អប្រសើរ នាងខ្ញុំសូមធ្វើការលើកយកនូវ ចំណោទបញ្ហាដែលពាក់ព័ន្ធនឹងបណ្តឹងទាស់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ មកធ្វើការចោទសួរដូចតទៅ៖

- តើអ្វីទៅជាបណ្តឹងទាស់?
- តើទម្រង់នៃបណ្តឹងទាស់ត្រូវធ្វើយ៉ាងដូចម្តេច?
- តើបណ្តឹងទាស់នេះត្រូវធ្វើនៅកន្លែងណា?
- តើអ្នកណាខ្លះអាចធ្វើបណ្តឹងទាស់នេះបាន?
- តើរយៈពេលប៉ុន្មានសម្រាប់ធ្វើបណ្តឹងទាស់នេះ?
- តើបណ្តឹងទាស់នេះមានអានុភាពអ្វីខ្លះ?
- តើតុលាការត្រូវសម្រេចយ៉ាងដូចម្តេចបន្ទាប់ពីមានការប្តឹងរួចហើយ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវរបស់នាងខ្ញុំ គឺដើម្បីចង់ស្វែងយល់អោយច្បាស់ពីនីតិវិធីនៅក្នុងប្រព័ន្ធតុលាការ ជាពិសេសគឺ តុលាការជាន់ដំបូង និងសាលាឧទ្ធរណ៍នៅព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែខ្ញុំបាទផ្តោតជាសំខាន់ទៅលើ បណ្តឹងទាស់ក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានចំណុចសំខាន់ៗមានជាអាទិ៍៖

- យល់អំពីបណ្តឹងទាស់នៃតុលាការជាន់ដំបូង និងសាលាឧទ្ធរណ៍
- យល់អំពីនីតិវិធីបន្ត បន្ទាប់ពីពុំសុខចិត្តនឹងសាលក្រមសាលាដំបូង

ការរៀបរៀងសារណានេះ ដើម្បីចូលរួមចំណែកដល់ ប្រជាពលរដ្ឋ និស្សិតគ្រប់ស្រទាប់ជាន់ថ្នាក់ ពិសេសមន្ត្រីរាជការកំពុងអនុវត្ត ដែលចង់ស្វែងយល់ផ្នែកច្បាប់នៅនីតិវិធីនៃការធ្វើ បណ្តឹងទាស់នេះ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការរៀបចំសារណានេះផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើ ដំណើរការនៃបណ្តឹងទាស់ ក្នុងរឿងព្រហ្មទណ្ឌ នៅតុលាការរាជធានី-ខេត្ត និងសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដែល និយាយអំពី របៀប ភាគី ទីកន្លែង រយៈពេល និងអានុភាពនៃការធ្វើបណ្តឹងទាស់នេះនិងនីតិវិធីនៃការ ដំណើរការបណ្តឹងទាស់របស់តុលាការ នាពេលបច្ចុប្បន្ន។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារណានេះពិតជាមានអត្ថប្រយោជន៍វិសេសវិសាលខ្លាំងណាស់ ដល់នាងខ្ញុំក៏ដូចជាមិត្តអ្នកអានទាំងអស់ មិនថាជាសិស្ស និស្សិត ឬក៏មន្ត្រីដែលកំពុងអនុវត្តន៍ច្បាប់អោយយល់ដឹងអំពីដំណើរការនៃការប្តឹងទាស់ និងនីតិវិធីមួយចំនួនដែលយកមកអនុវត្តចំពោះសំណុំរឿងនៅសភាព្រហ្មទណ្ឌ។ ព្រមទាំងមាននូវ គោលការណ៍មួយចំនួនដែលកំពុងតែអនុវត្តនាពេលបច្ចុប្បន្ន ដើម្បីផ្តល់ភាពងាយស្រួល ដល់ការសិក្សានីតិវិធី ក្នុងប្រព័ន្ធតុលាការ។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

ការរៀបចំសារណានេះជាចំបង គឺត្រូវចេះផ្តោតសំខាន់ទៅលើបណ្តាឯកសារ ឬលិខិតបទដ្ឋានគតិយុត្ត ទាំងឡាយណាដែលកំពុងយកមកអនុវត្តក្នុងពេលបច្ចុប្បន្ន ពិសេសគឺ ក្រមនីតិព្រហ្មទណ្ឌ។

❖ លំដាប់នៃការស្រាវជ្រាវគឺ

- ការជ្រើសរើសប្រធានបទ
- ការកំណត់អំពីចំណោទបញ្ហា
- ការកំណត់អំពីគោលដៅនៃការស្រាវជ្រាវ
- ការប្រមូលឯកសារពាក់ព័ន្ធ
- ការរៀបចំ និងសសេរពណ៌នាអំពីខ្លឹមសារ រួមទាំង សេចក្តីសន្និដ្ឋាន និងអនុសាសន៍នានា

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណា នាងខ្ញុំបានបែងចែកជា ២ជំពូកធំៗ គឺៈ

- ជំពូកទី១ៈ បណ្តឹងទាស់ទៅនឹងសាលក្រមរបស់តុលាការជាន់ដំបូង ដែលក្នុងនោះបានរៀបរាប់អំពី ទម្រង់ ទីកន្លែង ភាគី រយៈពេល អានុភាពនៃការធ្វើបណ្តឹងទាស់នឹង សាលក្រម របស់សាលាដំបូង។
- ជំពូកទី២ៈ បណ្តឹងឧទ្ធរណ៍ (បណ្តឹងទាស់ចំពោះសាលក្រមចំពោះមុខ) ដែលបានបកស្រាយយ៉ាងលម្អិតអំពីនីតិវិធី របស់ សាលាឧទ្ធរណ៍ លើសំណុំរឿងព្រហ្មទណ្ឌ។

បណ្តឹងទាស់ក្នុងរឿងព្រហ្មទណ្ឌនៅដំណាក់កាលសាលាឧទ្ធរណ៍នេះមានៈ ទម្រង់ ភាគី រយៈពេល ទីកន្លែង អានុភាព នៃការធ្វើបណ្តឹងទាស់ ដើម្បីអោយការស្រាវជាវមួយនេះមានភាពច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការស្វែងយល់បន្ថែមចំពោះអ្នកអាន។

ការពិពណ៌នាអំពីបញ្ហាទាំងនេះ នឹងត្រូវលើកមកពិភាក្សាដូចខាងក្រោមនេះ។

# ជំពូកទី១ បណ្ដឹងទាស់ទៅនឹងសាលក្រមតុលាការ

នៅក្នុងជំពូកទី១នៃសារណានេះសិក្សាទាក់ទងទៅនឹង បណ្ដឹងទាស់ទៅនឹងសាលក្រមតុលាការ។

មុននឹងឈានដល់ការបកស្រាយនោះ យើងត្រូវស្គាល់ជាមុនសិនថា អ្វីទៅជាបណ្ដឹងទាស់? ហើយអ្នកណាខ្លះជាភាគីនៃបណ្ដឹងទាស់? តើក្នុងការធ្វើបណ្ដឹងទាស់របស់ភាគីនីមួយៗនោះត្រូវចំណាយពេលប៉ុន្មាន? ក្រោយពីមានការធ្វើបណ្ដឹងទាស់រួចហើយតើវាមានអានុភាពយ៉ាងដូចម្ដេច? បន្ទាប់ពីមានការប្ដឹងទាស់តើតុលាការនឹងធ្វើការសម្រេចបែបណា?

## ១.១.និយមន័យនៃបណ្ដឹងទាស់

បណ្ដឹងទាស់ គឺជាផ្លូវតវ៉ាដែលធ្វើឡើងដើម្បីប្រឆាំងនឹងសាលក្រមកំបាំងមុខដែលបានចេញកំបាំងមុខជនជាប់ចោទ។ ពិរុទ្ធជនអាចធ្វើបណ្ដឹងទាស់នឹង សាលក្រមដែលប្រកាសកំបាំងមុខខ្លួនបាន។[១] មានន័យថានៅពេលដែលជនជាប់ចោទ មិនបានបង្ហាញខ្លួននាពេលសវនការទេ ឬមិនបានបង្ហាញភស្តុតាងឲ្យឃើញថាសាមីខ្លួនដឹងពី ការបញ្ជូនទៅជំនុំជម្រះ ឬបានដឹងពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទហើយសាលក្រមនេះបានបើកផ្លូវចំពោះការប្ដឹងទាស់។[២]

ដើមបណ្ដឹងរដ្ឋប្បវេណី[៣] ឬជាយថាហេតុ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី[៤] ក៏អាចត្រូវកាត់កំបាំងមុខដែរ ប្រសិនបើភាគីទាំងពីរនេះ មិនបានចូលបង្ហាញខ្លួននៅពេលសវនការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមនេះនឹងត្រូវកាត់កំបាំងមុខចំពោះភាគីទាំងពីរនេះ ដោយមានការជូនដំណឹងអំពីសាលក្រមកំបាំងមុខនេះ។ ប៉ុន្តែសាលក្រមនេះភាគីទាំងពីរអាចធ្វើការប្ដឹងទាស់បាន ក្នុងរយៈពេលសមស្របមួយ។

---

[១] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[២] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៣] វាក្យខ័ណ្ឌទី២ មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៤] វាក្យខ័ណ្ឌទី២ មាត្រា ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

### ១.២ ទម្រង់នៃបណ្តឹងទាស់

- ❖ បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ
- នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម
- នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[៥]
- កាលណាបានទទួលពាក្យបណ្តឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។
- កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខា អ្នកប្តឹងទាស់នោះត្រូវផ្តិតម្រាមដៃ។

### ១.៣ ទីកន្លែងសម្រាប់ធ្វើបណ្តឹងទាស់

ទីកន្លែងសម្រាប់ធ្វើការប្តឹង គឺវាអាស្រ័យទៅលើសមត្ថកិច្ចដែនដីរបស់តុលាការនីមួយៗមានជាអាទ៏ សាលាដំបូងរាជធានី-ខេត្ត អាស្រ័យទៅលើដើមហេតុនៃរឿងក្តីនោះកើតនៅទីណា។ ផ្ទុយពីនេះ ការប្តឹងទាស់ត្រូវធ្វើនៅតុលាការដែលបានជំនុំជម្រះរួចហើយបានធ្វើការកាត់កំបាំងមុខចំពោះភាគីណាមួយនៃរឿងក្តី ធ្វើអោយសាលក្រមនោះក្លាយជាសាលក្រមកំបាំងមុខមិនអាចធ្វើការប្តឹងឧទ្ធរណ៍បាន នោះភាគីទាំងនោះអាចធ្វើការប្តឹងទាស់បាន។

កាលណាទទួលពាក្យបណ្តឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន បញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម។[៦]

### ១.៤.ភាគីនៃបណ្តឹងទាស់

បណ្តឹងទាស់អាចធ្វើឡើងដោយ **ពិរុទ្ធជន** (១.៤.១) **ឬដើមបណ្តឹងរដ្ឋប្បវេណីជាយថាហេតុ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**(១.៤.២) អ្នកទាំងនេះអាចជាភាគីនៃបណ្តឹងទាស់ អាស្រ័យលើ កម្មវត្ថុ នៃបណ្តឹងទាស់ រួមទាំង**ព្រះរាជអាជ្ញា**(១.៤.៣) អាចជាភាគីនៃបណ្តឹងទាស់ផងដែរ។

---

[៥] វាក្យខ័ណ្ឌទី១ មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៦] វាក្យខ័ណ្ឌទី៣ មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

**១.៤.១ ពិរុទ្ធជន**

**១.៤.១.១ សញ្ញាណទូទៅនៃពិរុទ្ធជន**

ពាក្យថាពិរុទ្ធជន ត្រូវបានលើកយកមកប្រើ ក្រោយពីមានការជំនុំជម្រះ រហូតដល់ការប្រកាស សាលក្រមថា ជននោះមានពិរុទ្ធភាពបានប្រព្រឹត្តខុសពិតមែន។ តាមរយៈសាលក្រមដែលបញ្ជាក់ថាជននោះបានប្រព្រឹត្តខុស នោះជនជាប់ចោទដែលស្ថិតក្នុងការជំនុំជម្រះនឹងក្លាយទៅជា ពិរុទ្ធជនភ្លាមបន្ទាប់ពីមានការដាក់អោយ អនុវត្តសាលក្រម។ ដោយឡែកប្រសិនបើជនជាប់ចោទមិនមានទោសអ្វីទេជននោះនឹងត្រូវរួចផុតពី ការចោទប្រកាន់។

**១.៤.១.២ សិទ្ធ និងភាតព្វកិច្ចរបស់ពិរុទ្ធជន**

ទោះបីជាខ្លួនជាបុគ្គលដែលជាប់ចោទថាជា ពិរុទ្ធជនដែលបានធ្វើអោយ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈក៏ដោយ ប៉ុន្តែដើម្បីធានាបាននូវសុក្រឹត្យភាពនៃយុត្តិធម៌ ជននេះក៏នៅតែទទួលបានការយកចិត្តទុកដាក់ពីក្រមនីតិវិធីព្រហ្មទណ្ឌ ដូចជាភាគីដទៃផ្សេងទៀតដែរ។

ពិរុទ្ធជន មានសិទ្ធក្នុងការធ្វើការប្តឹងទាស់ទៅនឹងសាលក្រមដែល ប្រកាសកំបាំងមុខខ្លួនបាន។[៧] ប្រសិនបើ ពិរុទ្ធជននោះ ទទួលបានសាលក្រមកំបាំងមុខ ពិរុទ្ធជននោះហ្នឹងបាត់បង់សិទ្ធប្តឹងឧទ្ធរណ៍ ព្រោះមានតែសាលក្រមចំពោះមុខ និងសាលក្រមដែលចាត់ទុកថាចំពោះមុខ ប៉ុណ្ណោះទើបអាចធ្វើការប្តឹងឧទ្ធរណ៍បាន។[៨]

**១.៤.១.៣ បណ្តឹងទាស់ធ្វើឡើងដោយពិរុទ្ធជន**

ករណីដែលពិរុទ្ធជននោះមានមេធាវី នោះមេធាវីអាចធ្វើជាអ្នកតំណាងអោយពិរុទ្ធជននោះបានតែត្រូវមានលិខិតប្រគល់សិទ្ធ។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់ ប៉ុន្តែបើពិរុទ្ធជនជាអនីតិជន អាចត្រូវតំណាងដោយ ឪពុក ម្តាយ (អ្នកដែលមានអំណាចមេបា) ឬអ្នកអាណាព្យាបាល។ ករណីអ្នកតំណាងដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាល មិនចាំបាច់មានលិខិតប្រគល់សិទ្ធទេ។[៩]

[៧] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៨] វាក្យខ័ណ្ឌទី១ មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៩] វាក្យខ័ណ្ឌទី២ មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

ដរាបណាមានការប្តឹងទាស់អ្នកប្តឹងនោះត្រូវចុះហត្ថលេខានៅលើពាក្យប្តឹង បើអ្នកប្តឹងមិនចេះចុះហត្ថលេខាទេ ត្រូវផ្តិតមេដៃជំនួសវិញ។[១០]

### ១.៤.២ ដើមបណ្តឹងរដ្ឋប្បវេណី

#### ១.៤.២.១ សញ្ញាណទូទៅនៃដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។[១១] បណ្តឹងរដ្ឋប្បវេណីអាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបានដោយអ្នកតំណាង ស្របច្បាប់របស់ខ្លួនបាន កាលណាជនរងគ្រោះនេះជាអនីតិជន ឬជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ។[១២]

លើសពីនេះ យើងក៏ទទួលស្គាល់ផងដែរចំពោះការទទួលសិទ្ធដូចគ្នា ក្នុងការតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី របស់អង្គការសមូហភាពក្នុងករណីមួយចំនួន។ ការទទួលស្គាល់នេះហាក់ ដូចជា ត្រូវបានកម្រិតយ៉ាងតឹងរឹងចំពោះអង្គការទាំងនោះ ដែលតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ អង្គការសមូហភាពដែលអាចធ្វើបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន លុះត្រាតែអង្គការ ឬសមាគមនោះបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុត ៣(បី)ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស[១៣] ព្រមទាំងមានភស្តុតាងបញ្ជាក់ថា បានទទួលសិទ្ធនេះដោយមានការយល់ព្រមពីជនរងគ្រោះ ឬអ្នកតំណាងនៃជននោះ ឬពីសិទ្ធវន្តនៃជនរងគ្រោះ។[១៤]

សមាគមដែលអាចធ្វើ បណ្តឹងរដ្ឋប្បវេណី បានហើយ ទទួលស្គាល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌមានដូចខាងក្រោមនេះ៖

- ❖ សមាគមប្រយុទ្ធប្រឆាំងនឹង អំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារចំពោះបទល្មើសដែលមាន
    - ការបៀតបៀនដល់អាយុជិវិត
    - ការបៀតបៀនដល់រូបកាយ

---

[១០]វាក្យខ័ណ្ឌទី៤ មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[១១]វាក្យខណ្ឌទី១ មាត្រា ៥ នៃក្រមនីតិវីធីព្រហ្មទណ្ឌ២០០៧
[១២] មាត្រា ១៥ នៃក្រមនីតិវីធីព្រហ្មទណ្ឌ២០០៧
[១៣]វាក្យខណ្ឌទី១ មាត្រា ១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧
[១៤]មាត្រា ២០នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

- ការបៀតបៀនខាងផ្លូវភេទ។[១៥]

❖ សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រាត់ការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទចំពោះបទល្មើសដែលទាក់ទងនឹងកម្មវត្ថុនៃសលក្ខន្តិកៈរបស់ខ្លួន។[១៦]

❖ សមាគមប្រយុទ្ធប្រឆាំងនឹង ការប្រកាន់ពូជសាសន៍ និងការរើសអើង ចំពោះបទល្មើសដែលទាក់ទងនឹងការរើសអើង ការបៀតបៀនដោយចេតនាដល់រូបកាយ ឬអាយុជិវិតនិងការបំផ្លាញ ឬធ្វើអោយខូចខាត។[១៧]

បណ្តឹងរដ្ឋប្បវេណី ត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើសដើម្បី ទទួលបាននូវការជួសជុលព្យសនកម្ម។ ព្យសនកម្មត្រូវតែជាផលវិបាកផ្ទាល់នៃបទល្មើស និងជាព្យសនកម្មផ្ទាល់ខ្លួនហើយត្រូវបានកើតឡើងនៅក្នុងពេលបច្ចុប្បន្ន។ ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត។ [១៨]

គួរបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី ជាភាគីបណ្តឹងផ្នែករដ្ឋប្បវេណីនៃនីតិវិធីបណ្តឹងក្នុងសំណុំរឿងព្រហ្មទណ្ឌ។ រាល់សកម្មភាពរបស់ភាគីនេះត្រូវបានអនុញ្ញាតឱ្យត្រឹមសកម្មភាពណាដែលមានបំណងទាមទារនូវសំណង និងការជួសជុលព្យសនកម្មប៉ុណ្ណោះ។

**គ. ការជួសជុលព្យសនកម្ម**

ព្យសនកម្មអាចត្រូវបានជួសជុលដោយការបង់ជម្ងឺចិត្តដោយ ការសងទៅកាន់ជនរងគ្រោះវិញនូវ ទ្រព្យសម្បត្តិដែលបាត់បង់ ឬដោយការធ្វើអោយឱ្យដូចសភាពដើមវិញ នូវទ្រព្យសម្បត្តិ ដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើអោយខូចខាត។

សំណងជម្ងឺចិត្តដែលសងទៅជនរងគ្រោះ ត្រូវតែមានលក្ខណៈសមល្មមជាមួយនឹងព្យសនកម្ម ដែលត្រូវទទួលរង។[១៩]

[១៥] មាត្រា ១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[១៦] មាត្រា ១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[១៧] មាត្រា ១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[១៨] មាត្រា ១៣ នៃក្រមនីតិវីធីព្រហ្មទណ្ឌ២០០៧

[១៩] មាត្រា ១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

បញ្ញត្តិខាងលើនេះចង់បង្ហាញថា ជាគោលការណ៍ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែជាជនរងគ្រោះ ប៉ុន្តែបើជនរងគ្រោះនោះបានទទួលមរណភាពហើយ បណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តើមធ្វើ ឬបន្តធ្វើដោយសិទ្ធិវន្តរបស់ជនរងគ្រោះ។[២០]

**១.៤.២.២ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណី នេះមិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌក្រោយការផុត ចិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញា។[២១]

ការផុតរលត់នៃបណ្តឹងអាជ្ញាមានដូចតទៅៈ

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាច ចាប់ផ្តើមទៀតទេ ឬត្រូវតែបញ្ឈប់។[២២]

**១.៤.២.៣ សិទ្ធ និងភារកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[២៣] អាចធ្វើការប្តឹងទាស់នឹងសាលក្រមដែលសម្រេចដោយកំបាំងមុខខ្លួនបាន ប៉ុន្តែការប្តឹងទាស់នេះ ត្រូវកំណត់ទៅលើ សេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នៃសាលក្រមនោះតែប៉ុណ្ណោះ។[២៤] ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវ តំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ អ្នកតំណាងត្រូវមានលិខិតប្រគល់ សិទ្ធអោយ ប្តឹងទាស់។[២៥]

**១.៤.២.៤ សមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងក្នុងពេលជាមួយគ្នា នឹងបណ្តឹងអាជ្ញា នៅចំពោះមុខ សាលាជម្រះក្តីព្រហ្មទណ្ឌ។

[២០] មាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[២១] មាត្រា ២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[២២] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[២៣] វាក្យខ័ណ្ឌទី៥ មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[២៤] វាក្យខ័ណ្ឌទី១ មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[២៥] វាក្យខ័ណ្ឌទី៤ មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

បណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបានផងដែរ នៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី។ ក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិន ដរាបណាមិនទាន់មានសេចក្តីសម្រេច ជាស្ថាពរមួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។[២៦]

**១.៤.៣.ព្រះរាជអាជ្ញា**

**១.៤.៣.១សញ្ញាណទូទៅនៃព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា ជាអ្នកធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ ព្រះរាជអាជ្ញាជាអ្នកធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ។[២៧] ព្រះរាជអាជ្ញា ជាអ្នកអ្នកដើរតួយ៉ាងសំខាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ ក្នុងការការពារដល់ផល ប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈ និងជាអ្នកពិនិត្យឃ្លាំមើលការអនុវត្តច្បាប់ ប្រកបដោយប្រសិទ្ធភាព តាមរយៈបណ្តឹងអាជ្ញា គ្រប់ពេលដែលតុលាការធ្វើការជំនុំជម្រះរបស់ស្ថាប័នតុលាការ បើមានភាពមិនប្រក្រតីណាមួយ ព្រះរាជអាជ្ញាអាចធ្វើការប្តឹងទាស់ភ្លាមៗ ដូចជា ការដាក់ទណ្ឌកម្ម មិនសមស្របទៅនឹងការកំណត់របស់ច្បាប់ ធានាអោយបាននូវការអនុវត្តច្បាប់ដោយយុត្តិធម៌ និងតម្លាភាព។

**១.៤.៣.២ សិទ្ធ និងភាតព្វកិច្ចរបស់ព្រះរាជអាជ្ញា**

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាមានសិទ្ធ កេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ដើម្បីជាជំនួយ។[២៨] ទោះបីជាព្រះរាជអាជ្ញាមិនអាចធ្វើបណ្តឹងទាស់ក៏ដោយក៏ព្រះរាជអាជ្ញា នៅតែជាភាគីនៃបណ្តឹងទាស់របស់ពិរុទ្ធជន ដែលជំទាស់នឹងសាលក្រមផ្នែកព្រហ្មទណ្ឌជានិច្ច។ ពោលគឺ ព្រះរាជអាជ្ញា ទទួលបណ្តឹងទាស់របស់ពិរុទ្ធជន កាលណាពិរុទ្ធជនធ្វើបណ្តឹងទាស់ នៅចំពោះមុខខ្លួន ព្រះរាជអាជ្ញាត្រូវបញ្ជូនបណ្តឹងនេះទៅភ្លាមទៅ ក្រឡាបញ្ជីនៃតុលាការ ដែលចេញសាលក្រម។[២៩]

**១.៤.៣.៣ កម្មវត្ថុនៃបណ្តឹងអាជ្ញា**

បណ្តឹងអាជ្ញាអនុវត្តទៅលើ បុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥត ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពផ្សេងទៀតឡើយ។[៣០]

[២៦] មាត្រា ២២នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[២៧] វាក្យខណ្ឌទី១ មាត្រា២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[២៨] វាក្យខណ្ឌទី២ មាត្រា២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[២៩] ត្រទី២ វាក្យខ័ណ្ឌទី១ និងវាក្យខ័ណ្ឌទី៣ មាត្រា៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៣០] មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

**១.៤.៣.៤ ការចាប់ផ្តើមនៃបណ្តឹងអាជ្ញាដោយអយ្យការ**

បណ្តឹងអាជ្ញា ត្រូវបានអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់ពី បទព្រហ្មទណ្ឌ និងស្នើឱ្យមានការអនុវត្តច្បាប់នៅ ចំពោះមុខយុត្តាធិការ ជំនុំជម្រះ និងយុត្តាធិការស៊ើបសួរ។[៣១]

**១.៤.៣.៥ ការផុតរលត់នៃបណ្តឹងអាជ្ញា**

- ❖ មូលហេតុនៃការផុតរលត់នៃបណ្តឹងអាជ្ញា មានដូចតទៅ៖
- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ មិនអាចចាប់ផ្តើមទៀតបានទេ ឬត្រូវតែបញ្ឈប់។[៣២]

- ❖ មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា កាលណាច្បាប់ដោយឡែកបានចែងដោយ កំណត់ជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុត រលត់បានដែរ៖
- ដោយការសម្របសម្រួលជាមួយរដ្ឋ
- ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។[៣៣]

**១.៥.រយៈពេលក្នុងការធ្វើបណ្តឹងទាស់**

**១.៥.១ រយៈពេលធ្វើបណ្តឹងទាស់របស់ពិរុទ្ធជន**

- ❖ បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃផ្តើមគិត៖
- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខកាលណាសាលក្រម ត្រូវបានប្រគល់អោយពិរុទ្ធជនដោយផ្ទាល់ ឬ
- ពីថ្ងៃដែលជនអវត្តមាននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដែទេ។[៣៤]

---

[៣១] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៣២] មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៣៣] មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៣៤] មាត្រា៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

**១.៥.២ រយៈពេលធ្វើបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី**

❖ បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ គិតពីៈ

- ថ្ងៃឱ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមកំបាំងមុខបានប្រគល់អោយ ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។[៣៥]

**១.៦ អានុភាពនៃបណ្តឹងទាស់**

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនេះ ត្រូវទុកជាអសារបង់។ ការអនុវត្តសាលក្រមត្រូវព្យួរ ប៉ុន្តែដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែមានអានុភាព។ តុលាការនៅតែមានសមត្ថកិច្ចដើម្បី សម្រេចអំពីការដោះលែងជនជាប់ចោទអោយមានសេរីភាពវិញ។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេច ផ្នែករដ្ឋប្បវេណី នេះប៉ុណ្ណោះ ដែលត្រូវទុកជាអសារបង់។ ការអនុវត្តសេចក្តីសម្រេច ផ្នែករដ្ឋប្បវេណី នេះត្រូវព្យួរ។[៣៦]

**១.៧ សាលក្រមដែលសម្រេចលើបណ្តឹងទាស់**

សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅមុខតុលាការដដែល[៣៧] មានន័យថា នៅពេលដែលតុលាការ សម្រេចទទួលបណ្តឹងទាស់ហើយតុលាការត្រូវលើកយកសំណុំរឿងនេះមកជំនុំជម្រះ ដោយមានភាគីដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ នឹងត្រូវបានកោះហៅ តាមរយៈគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា។ នៅក្រោយពេលដែលតុលាការពិនិត្យមើល ពីភាពដែលអាចទទួលយកបាននៃបណ្តឹងទាស់នេះ តុលាការនឹងធ្វើការសម្រេចលើអង្គសេចក្តីជាថ្មីម្តង។ នៅក្នុងករណីដែលអ្នកប្តឹងទាស់ ដែលបានទទួលនូវការកោះហៅដោយត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅពេលសវនការទេ តុលាការនឹងប្រកាសថាបណ្តឹងទាស់នោះត្រូវរក្សាទុកជាឯកសារឥតបានការ។ សាលក្រមដែលគេប្តឹងទាស់នោះត្រូវរក្សាទុកដដែលមិនអាចកែប្រែបានទេ ដោយសាលក្រមនេះគឺមានអានុភាព ចំពោះភាគី ទាំងអស់ ដែលពាក់ព័ន្ធនឹងរឿងក្តីនេះ។

[៣៥] វាក្យខ័ណ្ឌទី២ មាត្រា៣៧២នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៣៦] មាត្រា ៣៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៣៧] មាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

# ជំពូកទី២៖ បណ្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរបស់តុលាការ

បន្ទាប់ពីបានស្វែងយល់អំពី ការធ្វើបណ្តឹងទាស់នៅជំពូកទី១ខាងលើនេះ រួចមក យើងបានដឹងហើយថា ការប្តឹងទាស់អាចធ្វើទៅបានដោយចំពោះសាលក្រមកំបាំងមុខ នៅក្នុងដំណាក់កាលតុលាការជាន់ដំបូង បន្ទាប់ពីតុលាការបានចេញសេចក្តីសម្រេច កំបាំងមុខ ភាគីណាមួយនៃរឿងក្តីរួចហើយ ភាគីនោះអាចធ្វើបណ្តឹងទាស់បាន ដើម្បី អោយតុលាការធ្វើការ សម្រេចសេចក្តីសារជាថ្មី ព្រោះនៅពេលដែលសាលក្រមកាត់ កំបាំងមុខរបស់ភាគីណាមួយ នៃរឿងក្តីភាគីនោះនឹងបាត់បង់សិទ្ធក្នុងការប្តឹងឧទ្ធរណ៍ (ការប្តឹងទាស់នឹងសាលក្រមចំពោះមុខ) ហេតុនេះទើប ក្រមនីតិវិធីព្រហ្មទណ្ឌ បាន អនុញ្ញាតអោយ ការប្តឹងទាស់ទៅលើសេចក្តីសម្រេច ដោយអាចដំណើរការទៅតាម នីតិវិធីមួយចំនួន និងមានរយៈពេលណាមួយកំណត់ច្បាស់លាស់។ បន្ទាប់ពីការប្តឹង ទាស់រួចហើយប្រសិន បើតុលាការធ្វើការសម្រេចថាចំពោះមុខវិញនោះ ភាគីទាំងនោះ អាចមានសិទ្ធ ក្នុងការប្តឹងឧទ្ធរណ៍បន្តទៅទៀតបាន។ ហេតុនេះហើយទើបជំពូកទី២នេះ និយាយអំពី **បណ្តឹងឧទ្ធរណ៍(បណ្តឹងទាស់ទៅនឹងសាលក្រមចំពោះមុខ)។**

ក្រោយពីទទួលបាននូវសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងរួចមក ប្រសិនបើ មានភាគីណាមួយនៃរឿងក្តី មិនសុខចិត្តនូវសេចក្តីសម្រេចណាមួយនោះភាគីទាំងនោះ មានសិទ្ធក្នុងការ ប្តឹងទាស់ចំពោះសាលក្រមចំពោះមុខបាន តាមរយៈការប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការសម្រេចនោះបានដោយមានដោយភាគីទាំងនោះត្រូវបំពេញនូវលក្ខខណ្ឌ មួយចំនួន។ មុននឹងឈានដល់ការប្តឹងឧទ្ធរណ៍នោះ យើងត្រូវស្គាល់ជាមុនសិនថា

តើអ្វីទៅជាបណ្តឹងឧទ្ធរណ៍? (២.១) កន្លែងណាដែលអាចប្តឹងឧទ្ធរណ៍បាន? (២.២) អ្នកណាខ្លះអាចធ្វើបណ្តឹងឧទ្ធរណ៍ បាន? (២.៣) ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ត្រូវចំណាយ រយៈពេល ប៉ុន្មាន?(២.៤) តើបណ្តឹងឧទ្ធណ៍នេះ មានអានុភាពយ៉ាងដូចម្តេច? (២.៥)

**២.១.និយមន័យ**

បណ្តឹងឧទ្ធរណ៍ជាផ្លូវតវ៉ានៃការកែប្រែ ដែលអូសបន្លាយការទទួលបាននូវ អាជ្ញាអស់ជំនុំ។ រឿងរ៉ាវត្រូវធ្វើនៅតុលាការដែលមានឋានានុក្រមខ្ពស់ជាង សាលក្រមដែលសម្រេចដោយ សាលាដំបូងនោះ។ បណ្តឹងនេះអាចធ្វើបានលុះតែសាលក្រមនោះជាសាលក្រមចំពោះមុខ[៣៨]និងសាលក្រមចាត់ទុកថាចំពោះមុខ[៣៩] ឬអាចនិយាយបានថា បណ្តឹងឧទ្ធរណ៍ជាបណ្តឹងទាស់ចំពោះសាលក្រមចំពោះមុខ នៅពេលដែលភាគីណាមួយនៃរឿងក្តីមិនសុខចិត្តនឹងសាលក្រមរបស់តុលាការជាន់ដំបូង។

**២.២. ទីកន្លែងសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍**

សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ មានសមត្ថកិច្ចដើម្បីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ ដែលធ្វើ ប្រឆាំងសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ក្នុងរឿងក្តី ព្រហ្មទណ្ឌ។[៤០]

**២.៣ ទម្រង់នៃបណ្តឹងឧទ្ធរណ៍**

**២.៣.១ ទម្រង់នៃបណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន**

❖ បណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជនត្រូវធ្វើដោយ

- ទម្រង់លាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជី នៃតុលាការដែលបានប្រកាសសាលក្រម។
- ក្រឡាបញ្ជី ត្រូវចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬអ្នកតំណាង។
- មានលិខិតប្រគល់សិទ្ធ ត្រូវភ្ជាប់ជាមួយលិខិតប្តឹងឧទ្ធរណ៍។

ពិរុទ្ធជនក៏អាចត្រូវតំណាងដោយមេធាវី ហើយមេធាវី ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធអោយធ្វើបណ្តឹងឧទ្ធរណ៍។

[៣៨] មាត្រា ៣៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៣៩] មាត្រា ៣៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៤០] មាត្រា ៣៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

ប៉ុន្តែបើពិរុទ្ធជនជាអនីតិជន អាចត្រូវតំណាងដោយ អ្នកដែលមាន អំណាចមេបា (ឪពុក ម្តាយ ឬអ្នកអាណាព្យាបាល) ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មាន លិខិតប្រគល់សិទ្ធទេ។[៩១]

### ២.៣.២ ទម្រង់នៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

❖ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើតាមរបៀបជាះ

- ទម្រង់លាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជី នៃតុលាការដែលបានប្រកាសសាលក្រម។
- ក្រឡាបញ្ជី ត្រូវចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។
- លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយ ក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬអ្នកតំណាង។ លិខិតប្រគល់សិទ្ធ ត្រូវភ្ជាប់ជាមួយលិខិតប្តឹងឧទ្ធរណ៍។

ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវតំណាងដោយ មេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធអោយធ្វើបណ្តឹងឧទ្ធរណ៍នេះ។[៩២]

### ២.៣.៣ ទម្រង់នៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

❖ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើដោយៈ

- ទម្រង់លាយលក្ខណ៍អក្សរ នៅការិយាល័យ ប្រឡាបញ្ជី នៃតុលាការ ដែលបានប្រកាសសាលក្រម។
- ក្រឡាបញ្ជី ចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជី នៃតុលាការ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬអ្នកតំណាង។ លិខិតប្រគល់សិទ្ធ ត្រូវភ្ជាប់ជាមួយ លិខិតប្តឹងឧទ្ធរណ៍។[៩៣]

[៩១] វាក្យខ័ណ្ឌទី១ និងទី២ ទី៥ មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៩២] វាក្យខ័ណ្ឌទី១ និងទី៣ ៤ ៥ មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៩៣] មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

**២.៣.៤ ទម្រង់នៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា**

❖ ការប្តឹងឧទ្ធរណ៍ របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាម

- ពាក្យប្តឹងនៅ ការិយាល័យ ក្រឡាបញ្ជីនៃ សាលាឧទ្ធរណ៍
- ក្រឡាបញ្ជី ចុះលិខិតប្តឹងឧទ្ធរណ៍នៅលើបញ្ជី ពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។
- លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និង អគ្គព្រះរាជអាជ្ញា។[៥៤]

**២.៤ ភាគីនៃបណ្តឹងឧទ្ធរណ៍**

បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បានមានដូចជា៖ ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍( តំណាងអយ្យការ) ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី (ចំពោះផលប្រយោជន៍ ផ្នែករដ្ឋប្បវេណី) ។[៥៥]

**២.៤.១ បណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន**

ពិរុទ្ធជនអាចធ្វើ បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសាលក្រម របស់តុលាការជាន់ដំបូង ដោយត្រូវគោរពទៅតាមនីតិវិធី ឬរបៀបនៃការប្តឹងដែលអាចទទួលយកបាន និងត្រូវគោរពទៅតាម ពេលវេលាដែលកំណត់ដោយច្បាប់ផងដែរ។

ក្នុងរយៈពេលប្តឹងឧទ្ធរណ៍ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ប៉ុន្តែជនជាប់ចោទដែលត្រូវបានជាប់ឃុំ ដែលបានចូលបង្ហាញខ្លួននៅចំពោះមុខ តុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារ នៅក្នុងរយៈពេលសម្រាប់ការប្តឹងឧទ្ធរណ៍របស់ ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍ លើសេចក្តីសម្រេចលើសំណុំរឿងព្រហ្មទណ្ឌនោះ ជនជាប់ចោទត្រូវនៅក្នុងពន្ធនាគារ រហូតដល់សាលាឧទ្ធរណ៍ ធ្វើការសម្រេចសេចក្តីចប់។

ក្នុងករណីដែលតុលាការជាន់ដំបូងសម្រេចអោយរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬស្មើនឹងរយៈពេល នៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញា អាចយល់ព្រមដោះលែង ជនជាប់ចោទឲ្យមានសេរីភាព មុនពេលផុតកំណត់រយៈពេលសម្រាប់ ប្តឹងឧទ្ធរណ៍។[៥៦]

[៥៤] មាត្រា៣៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[៥៥] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[៥៦] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

### ២.៤.២ បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើបណ្ដឹងឧទ្ធរណ៍បាន ដែលបណ្ដឹងនេះត្រូវធ្វើតាមទម្រង់ និងរយៈពេលដែលកំណត់ដោយច្បាប់។ ដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើបណ្ដឹងឧទ្ធរណ៍បានតែចំពោះផលប្រយោជន៍រដ្ឋប្បវេណីប៉ុណ្ណោះ។[៤៧]

ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវតំណាងដោយ មេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដែលអ្នកទាំងនេះត្រូវមានលិខិតប្រគល់សិទ្ធអោយ ប្ដឹងឧទ្ធរណ៍។[៤៨] លិខិតប្រគល់សិទ្ធត្រូវតែមានចុះហត្ថលេខា ឬផ្ដិតម្រាមដៃដោយអ្នកប្ដឹង ឬអ្នកតំណាងរួមជាមួយក្រឡាបញ្ជី។[៤៩]

### ២.៤.៣ បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺជាភាគីតំណាងឲ្យរដ្ឋ អាចធ្វើបណ្ដឹងឧទ្ធរណ៍ទៅនឹងសាលក្រមរបស់តុលាការជាន់ដំបូង។ ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចដែនដី អាចធ្វើបណ្ដឹងប្រឆាំងសេចក្ដីសម្រេចតែ ផ្នែកព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធផ្នែក រដ្ឋប្បវេណីទេព្រោះ អយ្យការ តំណាងឲ្យសាធារណៈ មិនតំណាងអោយប្រយោជន៍ឯកជនទេ។ ទោះបីតំណាងអយ្យការជាតំណាងអោយរដ្ឋរក្សាការពារប្រយោជន៍សាធារណៈ ក៏ដោយក៏សកម្មភាព របស់អយ្យការត្រូវបានកម្រិត ហើយរាល់សកម្មភាពទាំងឡាយត្រូវអនុវត្តទៅ តាមនីតិវិធីច្បាប់ផងដែរ។

### ២.៤.៤ បណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

អគ្គព្រះរាជអាជ្ញា គឺជាអ្នកតំណាងនៃអង្គការអយ្យការអមសាលាឧទ្ធរណ៍។[៥០]

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអ្នកឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។ មានន័យថា អគ្គព្រះរាជអាជ្ញា ជាអ្នកដើរតួយ៉ាងសំខាន់មួយរូប ក្នុងនាមជាអ្នកការពារផលប្រយោជន៍សាធារណៈ និងការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ ភាពត្រឹមត្រូវ ដោយធានាអោយបាននូវសមមូល ក្នុងការអនុវត្តច្បាប់ជាធរមាន។

---

[៤៧] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៤៨] វាក្យខ័ណ្ឌទី១ និងទី៣ មាត្រា ៣៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៤៩] វាក្យខ័ណ្ឌទី៣ មាត្រា ៣៧៦នៃក្រមនីតិវិធីទណ្ឌ ២០០៧

[៥០] មាត្រា៣៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

## ២.៥.រយៈពេលប្តឹងឧទ្ធរណ៍

### ២.៥.១ រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន

បណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជនត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេល ប្រកាសសាលក្រម។ ដោយឡែកសាលក្រមចាត់ទុកជាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការអោយដំណឹងនេះ ធ្វើតាមវិធីណាក៏ដោយ។[៥១]

ករណីបណ្តឹងឧប្បដិហេតុ ពិរុទ្ធជនមានរយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧប្បដិហេតុ ក្នុងករណីដែលភាគីដទៃបានធ្វើបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេលខាងលើ។ រយៈពេលបន្ថែមគិតចាប់ពីការផុតរយៈពេលធម្មតា។[៥២]

ក្នុងករណីមានការឃុំខ្លួនពិរុទ្ធជនមានរយៈពេលប្តឹងឧទ្ធរណ៍ចំនួន ៥ (ប្រាំ) ថ្ងៃផ្តើមគិតពីពេលដែលតុលាការសម្រេចពីការឃុំខ្លួន។[៥៣]

### ២.៥.២ រយៈពេលប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម។ ដោយឡែកសាលក្រមចាត់ទុកជាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការអោយដំណឹងនេះធ្វើតាមវិធីណា ក៏ដោយ។[៥៤]

ដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើ បណ្តឹងឧប្បដិហេតុ ក្នុងករណីដែលភាគីដទៃបានធ្វើបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេលខាងលើ ១ (មួយ) ខែ។ រយៈពេលបន្ថែមគិតចាប់ពីការផុតរយៈពេលធម្មតា។[៥៥]

### ២.៥.៣ រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម។ ក្នុងករណីដែលតុលាការបាន សម្រេចផ្តន្ទាទោសជននោះ តិចពេកមិន សមមូលទៅនឹងការកំណត់របស់ច្បាប់ជាធរមាន ព្រះរាជអាជ្ញាជាអ្នកដើរតួក្នុងការប្តឹងឧទ្ធរណ៍។

[៥១] មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥២] មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥៣] មាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥៤] មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥៥] មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

#### ២.៥.៤ រយៈពេលប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ៣ (បី) ខែគិតចាប់ពីពេលប្រកាសសាលក្រម។[៥៦] ក្នុងករណីដែលតុលាការបាន សម្រេចផ្តន្ទាទោសជននោះ តិចពេកមិនសមមូលទៅនឹងការកំណត់របស់ច្បាប់ជាធរមាន អគ្គព្រះរាជអាជ្ញាជាអ្នកដើរតួក្នុងការប្តឹងឧទ្ធរណ៍។

### ២.៦. អានុភាពនៃបណ្តឹងឧទ្ធរណ៍

#### ២.៦.១ អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម

នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែ ជនជាប់ចោទ ដែលជាប់ឃុំដែលបានចូលខ្លួននៅមុខតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងសំណុំរឿងព្រហ្មទណ្ឌ នោះជនជាប់ចោទ ត្រូវនៅក្នុងពន្ធនាគារដល់ការសម្រេចចុងក្រោយរបស់ សាលាឧទ្ធរណ៍ តាមរយៈសាលដីកា។

ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចអោយរួចខ្លួន បានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញា អាចយល់ព្រមឱ្យមានការដោះលែង ជនជាប់ចោទឱ្យមានសេរីភាពវិញបាន មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។[៥៧]

#### ២.៦.២ អានុភាពនៃបណ្តឹងឧទ្ធរណ៍លើជនជាប់ចោទ

សាលាឧទ្ធរណ៍ កាលណាបានទទួលពាក្យបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះមិនអាចដាក់ទម្ងន់លើជននោះបានទេ។ តុលាការអាចកែប្រែសាលក្រមបាននៅក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ។ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោស ពីលើ មូលទោស បានទេ។

សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើស ដែលបានកំណត់ ដោយតុលាការជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែមិនអាចដាក់បន្ថែមទម្ងន់ទោសលើជនជាប់ចោទនេះបានទេ។

ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយ ដែលដាច់ខាតត្រូវតែប្រកាសនោះសាលាឧទ្ធរណ៍អាចបដិសេធសាលក្រម ហើយសម្រេចអំពីទោស

---

[៥៦] មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥៧] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

ជាថ្មីម្តងទៀត។ កាលណាបានទទួលបណ្តឹងតែពីជនជាប់ចោទប៉ុណ្ណោះ សាលាឧទ្ធរណ៍ មិនអាចបន្ថែម ចំនួនទឹកប្រាក់សម្រាប់ជួសជុលខូចខាត ដល់ដើមបណ្តឹងរដ្ឋប្បវេណី ទេ។[៥៨]

### ២.៦.៣ អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញានាំឱ្យសើរើឡើងវិញ នូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៃតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ជាយថាហេតុ អាចបដិសេធសាលក្រមដែលនាំឱ្យរួចខ្លួន ឬអាចសម្រេចឱ្យជនជាប់ចោទរួចខ្លួនជានិច្ច ប្រសិនបើយល់ឃើញថាមានពិរុទ្ធភាពលើជននេះមិនអាចបង្ហាញអោយឃើញទេ។

សាលាឧទ្ធរណ៍ អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានតែបាន ដែលតុលាការជាន់ភ្លេចមិនបានប្រកាស។

### ២.៦.៤ អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា នាំឱ្យសើរើឡើងវិញ នូវសេចក្តីសម្រេចខាងសំណុំរឿងព្រហ្មទណ្ឌ នៃតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ជាយថាហេតុ អាចបដិសេធសាលក្រម ដែលនាំឱ្យរួចខ្លួន ឬអាចសម្រេចឱ្យជនជាប់ចោទរួចខ្លួនជានិច្ច ប្រសិនបើយល់ឃើញថា មានពិរុទ្ធភាពលើជននេះមិនអាចបង្ហាញអោយឃើញទេ។

សាលាឧទ្ធរណ៍អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានតែបាន ដែលតុលាការជាន់ភ្លេចមិនបានប្រកាស។[៥៩]

### ២.៦.៥ អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ប៉ុណ្ណោះ។ នៅមុខសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចធ្វើពាក្យប្តឹងសុំថ្មី ដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ។[៦០]

### ២.៦.៦ បណ្តឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន

កាលណាសាលាឧទ្ធរណ៍យល់ឃើញថា បណ្តឹងឧទ្ធរណ៍ធ្វើហួសពេលកំណត់ ឬធ្វើនៅក្នុងលក្ខខណ្ឌមិនត្រឹមត្រូវនោះ សាលាឧទ្ធរណ៍ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។[៦១]

[៥៨] មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧
[៥៩] មាត្រា ៤០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧
[៦០] មាត្រា៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[៦១] មាត្រា៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

### ២.៦.៧ ការបដិសេធសាលក្រម

សាលាឧទ្ធរណ៍យល់ឃើញថា គ្មានពិរុទ្ធភាពលើជនជាប់ចោទទេ ឬក៏អំពើនោះមិនមែនជាបទល្មើសទេ សាលាឧទ្ធរណ៍បដិសេធសាលក្រម ហើយអោយជនជាប់ចោទរួចខ្លួន។[៦២]

កាលណាសាលាឧទ្ធរណ៍ពិនិត្យ មើលឃើញថា សាលក្រមរបស់តុលាការជាន់ដំបូង មានជាប់មោឃភាព សាលាឧទ្ធរណ៍ អាចសម្រេចលើអង្គសេចក្តីឡើងវិញដូចតុលាការ ជាន់ដំបូងដែរ។[៦៣]

### ២.៦.៨ ដីកាបង្គាប់ឱ្យឃុំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួនដោយសាលាឧទ្ធរណ៍

ប្រសិនបើសាលាឧទ្ធរណ៍សម្រេចទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ ដោយគ្មានការព្យួរទេ ហើយប្រសិនបើវិធានការសន្តិសុខតម្រូវនោះ សាលាឧទ្ធរណ៍ តាមរយៈសេចក្តីសម្រេច មានលក្ខណៈពិសេស និងមានសំអាងហេតុ អាចចេញនៅពេលសវនាការនូវ៖

- ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន
- ដីកាដែលបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលអវត្តមាន
- ដីកាបង្គាប់ឱ្យឃុំ និងដីកាបង្គាប់ឱ្យចាប់ខ្លួនមានអានុភាពអនុវត្តភ្លាម។

❖ ដីកាទាំងនេះមានចុះនិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណនៃពិរុទ្ធជន
- ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃទណ្ឌកម្មនេះ
- ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។

ដីកាទាំងនេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនោះ និងមាន បោះត្រាផង។ ពិរុទ្ធជនដែលត្រូវចាប់ខ្លួនត្រូវអនុវត្តតាម ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវនាំខ្លួន ក្នុងរយៈពេលដ៏ខ្លីបំផុតទៅ បង្ហាញជូនព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនដែលត្រូវឱ្យដំណឹង ពីដីកានេះដល់សាមីខ្លួន និងធ្វើការឃុំ ខ្លួនជននោះ។[៦៤]

## ២.៧ អានុភាពនៃសាលដីកា

### ២.៧.១ អានុភាពនៃការអនុវត្ត

សាលដីការបស់សាលាឧទ្ធរណ៍ គឺជាសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងលើសាលក្រម និងសេចក្តីសម្រេចនានារបស់តុលាការថ្នាក់ក្រោម។ សាលដីកានេះជាគោលការណ៍ត្រូវតែប្រកាសជាសាធារណៈ ហើយរៀងរាល់លើកត្រូវតែកែ ធ្វើឡើង

[៦២] មាត្រា៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៦៣] មាត្រា៤០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៦៤] មាត្រា៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

វិញ ដោយប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ ប្រកបដោយសម្លេង ខ្លាំងៗ ច្បាស់លាស់ និងគ្មានសម្លេងបន្លំ។

ការប្រកាសសាលដីកានេះតំរូវអោយប្រកាសក្នុងនាមប្រជារាស្ត្រខ្មែរ ហើយផ្នែកចាំបាច់នៃសាលដីកាដែលត្រូវប្រកាសនោះ គឺផ្នែកសំអាងហេតុ និងផ្នែកសេចក្តីសម្រេចរបស់សាលដីកា ទោះបីជាចំពោះមុខ ឬកំបាំងមុខរបស់ភាគីណាមួយនៃរឿងក្តីក៏ដោយ នៅពេលសាលដីកាសាលាឧទ្ធរណ៍ ចូលជាស្ថាពរ ហើយអានុភាពអនុវត្តមានវិសាលភាពទូទាំងផ្ទៃប្រទេស ហើយសាលដីកា នេះក៏មានការបើកផ្លូវអោយធ្វើការប្តឹងទាស់ផងដែរ ដោយមានរយៈពេលកំណត់ដោយច្បាប់ជាធរមាននាពេលបច្ចុប្បន្ន នៃព្រះរាជាណាចក្រកម្ពុជា។

### ២.៨ បណ្តឹងទាស់ទៅនឹងសាលដីកាចេញដោយកំបាំងមុខ

បណ្តឹងទាស់ទៅនឹងសាលដីកា គឺជា បណ្តឹងទាស់មួយ ដែលធ្វើឡើងប្រឆាំងនឹងសាលដីកាកំបាំងមុខខ្លួន។[៦៥]

#### ២.៨.១ ទម្រង់នៃបណ្តឹងទាស់

#### ២.៨.១.១ ទម្រង់នៃបណ្តឹងទាស់របស់ពិរុទ្ធជន

❖ បណ្តឹងទាស់អាចត្រូវធ្វើឡើង ដូចខាងក្រោមនេះ៖

- តាមពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ ដែលបានសម្រេចចេញសាលដីកា ឬ
- តាមពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរនៅចំពោះមុខអគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។
- កាលណាបានទទួលពាក្យបណ្តឹងទាស់ អគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បញ្ជូនសំណុំរឿង នោះភ្លាមទៅ សាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកា។
- កាលណាអ្នកប្តឹងទាស់មិនចេះហត្ថលេខាទេ សាមីខ្លួនត្រូវផ្តិតម្រាមដៃ។

ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី ហើយមេធាវី ត្រូវតែមានលិខិតអនុញ្ញាតអោយធ្វើបណ្តឹងទាស់។ ប៉ុន្តែប្រសិនបើពិរុទ្ធជនជាអនីតិជនវិញ អាចត្រូវតំណាងដោយអ្នកដែលមាន អំណាចមេបា ( ឪពុក ម្តាយ ឬអ្នកអាណាព្យាបាល) ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មាន លិខិតប្រគល់សិទ្ធទេ។[៦៦]

---

[៦៥] មាត្រា ៤០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៦៦] មាត្រា ៤១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

**២.៨.១.២ ទម្រង់នៃបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក៏អាចប្តឹងទាស់នឹងសាលដីកាកំបាំងមុខខ្លួនបានផងដែរ។ បណ្តឹងទាស់នេះ កំណត់ទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកានោះប៉ុណ្ណោះ។

❖ បណ្តឹងទាស់អាចធ្វើទៅបានដោយ

- លាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ដែលបានប្រកាសសាលដីកា។

ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមាន លិខិតប្រគល់សិទ្ធ ជាលាយលក្ខណ៍អក្សរដែលអនុញ្ញាតអោយប្តឹងទាស់។[៦៧]

**២.៨.២ ភាគីដែលអាចប្តឹងទាស់**

គ្រប់ភាគីនៃរឿងក្តីទាំងអស់សុទ្ធតែអាចធ្វើការប្តឹងទាស់បាន បន្ទាប់ពីមានការធ្វើសេចក្តីសម្រេចកំបាំងមុខ ភាគីណាមួយហើយភាគីទាំងនោះអាចធ្វើការប្តឹងទាស់ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនក្នុងការមានសិទ្ធ ប្តឹងសារទុក្ខ បន្តទៀត ប្រសិនមិនសុខចិត្តនឹងការសម្រេចណាមួយក្នុងសាលដីកា។

ប្រសិនបើតុលាការធ្វើការកាត់ក្តីកំបាំងមុខភាគីណាមួយនៃរឿងក្តីហើយ ភាគីនេះមិនបាន ធ្វើការប្តឹងទាស់ទេ ភាគីនោះនឹងបាត់បង់សិទ្ធប្តឹងសារទុក្ខ។

ភាគីនៃរឿងក្តី មានជាអាទិ៍ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

**២.៨.៣ រយៈពេលនៃបណ្តឹងទាស់**

**២.៨.៣.១ រយៈពេលនៃបណ្តឹងទាស់របស់ពិរុទ្ធជន**

❖ ពិរុទ្ធជនត្រូវធ្វើបណ្តឹងទាស់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពី៖

- ថ្ងៃឱ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលដីកានេះ ត្រូវបានប្រគល់ឱ្យដល់ ពិរុទ្ធជនផ្ទាល់ដៃ។
- ថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃទេ។[៦៨]

[៦៧] វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៦៨] មាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

### ២.៨.៣.២ រយៈពេលនៃបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី

❖ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើបណ្តឹងទាស់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីៈ

- ថ្ងៃឱ្យដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះ ត្រូវបាន ប្រគល់អោយដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកា នេះមិនបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្ទាល់ ដៃទេ។[៦៩]

### ២.៨.៤ បណ្តឹងទាស់ចំពោះសេចក្តីសម្រេចផ្នែកព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី

បណ្តឹងទាស់ដែលធ្វើការប្រឆាំងនឹងសេចក្តីសម្រេចនៃសាលដីកាទាំងមូល ត្រូវទុកជាអសារបង់ហើយការអនុវត្តនៃសាលដីកាត្រូវព្យួរ។ ប៉ុន្តែដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព។ សាលាឧទ្ធរណ៍ នៅតែមានសមត្ថកិច្ច ដើម្បីសម្រេចពីការដោះលែងអោយមានសេរីភាពឡើងវិញ។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នោះសេចក្តីសម្រេច ត្រង់ផ្នែកនេះត្រូវទុកជាអសារបង់ ហើយការអនុវត្តត្រូវព្យួរ។[៧០]

### ២.៨.៥ សាលដីកាសម្រេចលើបណ្តឹងទាស់

សាលដីកាដែលចេញតាមបណ្តឹងទាស់ សំណុំរឿងត្រូវលើកមកជំនុំជំរះនៅមុខសាលាឧទ្ធរណ៍ដដែល។ គូភាគីនៃ សំណុំរឿង ត្រូវបានកោះហៅតាមគំនិតផ្តួចផ្តើមដោយអគ្គព្រះរាជអាជ្ញា។ ក្រោយពីសម្រេចលើភាពដែលអាចទទួលយកបាន នៃ បណ្តឹងទាស់ តុលាការនឹងសម្រេចសារជាថ្មីលើអង្គសេចក្តី។

ប្រសិនបើអ្នកប្តឹងទាស់ដែលបានកោះហៅយ៉ាងត្រឹមត្រូវហើយ តែមិនចូលមកបង្ហាញខ្លួននៅពេលសវនការ តុលាការប្រកាសថាបណ្តឹងទាស់ ត្រូវទុកជាអសារឥតការ។ សាលដីកាដែលប្តឹងទាស់មិនអាចត្រូវបានកែប្រែបានទេ។ សាលដីកានេះមានអានុភាពទាំងស្រុងចំពោះគូភាគី។ ប៉ុន្តែពិរុទ្ធជនអាចធ្វើការប្តឹងតវ៉ាបន្តទៅតុលាការកំពូលទៀតបាន។[៧១]

[៦៩]វាក្យខណ្ឌទី២ មាត្រា៤១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៧០] មាត្រា ៤១៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៧១] មាត្រា ៤១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

## ២.៩ បណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ ជាបណ្តឹងដែលធ្វើឡើងដោយប្រឆាំងនូវសាលដីការបស់ សាលាឧទ្ធរណ៍ ហើយគិតបញ្ចូលទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលជា សមត្ថកិច្ចចុងក្រោយរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។[៧២]

បណ្តឹងសាទុក្ខនេះត្រូវពិនិត្យមើលដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល។[៧៣]

### ២.៩.១ បុគ្គលដែលអាចប្តឹងសាទុក្ខ

❖ បណ្តឹងសាទុក្ខត្រូវធ្វើឡើងដោយ៖

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ជនជាប់ចោទ ឬពិរុទ្ធជន
- បុគ្គលដែលត្រូវគេទាមទារ ក្នុងករណីនៃនីតិវិធីបត្យាប័ន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[៧៤]

### ២.៩.២ មូលហេតុនៃបណ្តឹងសាទុក្ខ

❖ តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចក្នុងករណីដូចតទៅ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថកិច្ចនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពានភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគីកាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានអង្គហេតុ
- ការផ្ទុយគ្នារវាងអង្គហេតុ និងសេចក្តីសម្រេច។[៧៥]

---

[៧២] វាក្យខ័ណ្ឌទី១ មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៧៣] វាក្យខ័ណ្ឌទី២ មាត្រា ៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៧៤] វាក្យខ័ណ្ឌទី១ មាត្រា ៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៧៥] មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

### ២.៩.៣ ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ

#### ២.៩.៣.១ ទម្រង់នៃបណ្តឹងសាទុក្ខរបស់ពិរុទ្ធជន

បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ។

ជនជាប់ចោទ ពិរុទ្ធជន អាចត្រូវតំណាងដោយមេធាវី។ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធ ប៉ុន្តែជនជាប់ចោទ ឬពិរុទ្ធជន ជាអនីតិជនអាចត្រូវតំណាងដោយ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មាន លិខិតប្រគល់សិទ្ធទេ។[៧៦]

#### ២.៩.៣.២ ទម្រង់នៃបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ន្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធឱ្យធ្វើបណ្តឹងសាទុក្ខនេះ។[៧៧]

#### ២.៩.៣.៣ ការចុះហត្ថលេខាលើបណ្តឹងសាទុក្ខ

បណ្តឹងសាទុកត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹង ឬអ្នកតំណាង ។ កាលណាអ្នកប្តឹងមិនចេះចុះហត្ថលេខាទេ សាមីខ្លួន ឬអ្នកតំណាងត្រូវផ្តិតម្រាមដៃ។ លិខិតប្រគល់សិទ្ធត្រូវភ្ជាប់ជាមួយនឹងពាក្យសុំប្តឹងសាទុក្ខ។

ប្រសិនបើខ្វះហត្ថលេខា របស់ក្រឡាបញ្ជី ឬខ្វះកាលបរិច្ឆេទ ពាក្យប្តឹងសាទុក្ខអាចទទួលបានប្រសិនបើគ្មានឃើញការបន្លំអ្វីទេ។ ក្រឡាបញ្ជីត្រូវរងទោសពិន័យ ៥.០០០ (ប្រាំពាន់) រៀល។ ប្រាក់ពិន័យនេះ ត្រូវប្រកាសដោយតុលាការកំពូលនៅក្នុងសាលដីការបស់ខ្លួន។[៧៨]

### ២.៩.៤ រយៈពេលដើម្បីធ្វើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេល ១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

[៧៦] វាក្យខ័ណ្ឌទី១ និង ២ មាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[៧៧] វាក្យខ័ណ្ឌទី២ និង ៣ មាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
[៧៨] មាត្រា ៤២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា។

កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្តើមពីការឱ្យដំណឹង។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់។[៧៩]

### ២.៩.៥ ការបញ្ជូនសំណុំរឿងទៅតុលាការកំពូល

នៅក្នុងរយៈពេលដ៏ខ្លីបំផុត ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍រៀបចំសំណុំរឿង ហើយបញ្ជូនទៅក្រឡាបញ្ជីតុលាការកំពូល។[៨០] នៅពេលដែលសំណុំរឿងបានទៅដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវធ្វើការចុះបញ្ជី។[៨១]

### ២.៩.៦ ករណីបង្វិលពីតុលាការកំពូល

សាលាឧទ្ធរណ៍មិនត្រឹមតែមានសមត្ថកិច្ចជំនុំជម្រះលើសាលក្រម ឬសេចក្តីសម្រេចនានារបស់តុលាការថ្នាក់ក្រោ កាលណាមានបណ្តឹងឧទ្ធរណ៍នោះទេ ហើយថែមទាំងមានសមត្ថកិច្ចជំនុំជម្រះទៅលើសំណុំរឿងទាំងឡាយ ដែលបានបង្វិលមកពីតុលាការកំពូលផងដែរ។ ក្នុងករណីដែល តុលាការកំពូលពិនិត្យមើលឃើញថាសាលដីការបស់សាលាឧទ្ធរណ៍ មានលក្ខណៈពុំត្រឹមត្រូវតាម ច្បាប់នោះតុលាការកំពូលអាចបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូលតែម្តង ដោយសារមានបណ្តឹងសាលទុក្ខលើគ្រប់ចំណុចនៃសាលដីកានោះ។ ដូច្នេះតុលាការកំពូលត្រូវបញ្ជូនសំណុំរឿងនោះសារជាថ្មីឡើងវិញ។ ក្រុមប្រឹក្សាជំនុំជម្រះបីរូប ដែលបានជម្រះលើសំណុំរឿងនេះពីមុនមិនអាចធ្វើជាសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ លើសំណុំរឿងជាលើកទីពីរទៀតបានទេ។ សមាសភាពក្រុមប្រឹក្សាដែលមានការចាត់តាំងពីប្រធានសាលាឧទ្ធរណ៍។ ក្នុងករណីដែលតុលាការកំពូលបដិសេធសាលដីកា របស់សាលាឧទ្ធរណ៍ លើចំណុចណាមួយដែលមានបណ្តឹងសារទុក្ខ នោះចំណុចដែលពុំបានប្តឹងនៅតែមានតម្លៃដដែលហើយតុលាការកំពូលអាចចង្អុលបង្ហាញអំពីការយល់ឃើញរបស់ខ្លួន ចំពោះចំណុចដែលប្តឹងសារទុក្ខ អោយក្រុម ប្រឹក្សាជំនុំជម្រះពិនិត្យមើល និងសម្រេចឡើងវិញ។ ការជំនុំជម្រះលើកទីពីរនេះសាលាឧទ្ធរណ៍ ពិនិត្យតែទៅលើចំណុចដែលតុលាការកំពូលបានចង្អុលបង្ហាញប៉ុណ្ណោះ។

---

[៧៩] មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៨០] មាត្រា ៤២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[៨១] មាត្រា ៤២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សា និងការបង្ហាញអំពីដំណើរការនៃបណ្តឹងទាស់ ក្នុងសំណុំរឿងព្រហ្មទណ្ឌ រួចមកឃើញថា ការធ្វើបណ្តឹងទាស់នេះ អាចធ្វើទៅបានគ្រប់សមត្ថកិច្ចនៃស្ថាប័នតុលាការ មានជាអាទិ៍ នៅដំណាក់កាលតុលាការជាន់ដំបូង អាចធ្វើការប្តឹងទាស់ទាំងលើ សាលក្រមកំបាំងមុខ ដើម្បីឱ្យខ្លួនមានសិទ្ធក្នុងការប្តឹងឧទ្ធរណ៍ (ប្តឹងទាស់ចំពោះសាលក្រមចំពោះមុខ) និងប្តឹងទាស់ទៅលើសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍បន្ត អាចប្តឹងទាស់រហូតដល់បណ្តឹងសាទុក្ខបន្តទៀតបាន។ ភាគីដែលសកម្ម និងតែងតែមានវត្តមាននៅពេលមានការប្តឹងទាស់នោះមានដូចជាជនជាប់ចោទ ឬពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះនៃរឿងក្តី ក៏អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរ និងពិសេសទៅទៀតនោះគឺ តំណាងអយ្យការ (ព្រះរាជអាជ្ញាឬអគ្គព្រះរាជអាជ្ញា) ជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការប្តឹងទាស់នេះ មិនអាចអវត្តមានរបស់តំណាងអយ្យការនាពេលសវនាការឡើយព្រោះតំណាងអយ្យការ ជាភាគីដែលតំណាងឱ្យរដ្ឋក្នុងការថែរក្សា ការពារ សណ្តាប់ធ្នាប់សាធារណៈ និងជាអ្នកឃ្លាំមើលការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព យុត្តិធម៌។ ចំណែកឯជនដែលត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើសវិញនៅតែទទួលបាននូវការគោរពសិទ្ធជាបុគ្គលឯកជនដោយមិនអាចមានការជ្រៀតជ្រែកមិនសមរម្យណាមួយពីអាជ្ញាធរមានសមត្ថកិច្ច។ រាល់ការឃាត់ ឬ ឃុំខ្លួន អាចធ្វើទៅបានលុះត្រាតែស្ថិតក្នុងស្ថានភាពចាំបាច់ និងត្រូវធ្វើឡើងដោយមានដីកា និងត្រូវគោរពតាមនីតិវិធីច្បាប់។ ពិរុទ្ធជន អាចមានសិទ្ធគ្រប់គ្រាន់ក្នុងការប្តឹងទាស់នឹងសាលក្រម ឬសាលដីកាដែលបានសម្រេចដោយតុលាការណាមួយ។

គ្រប់ភាគីទាំងអស់នៃរឿងក្តីសុទ្ធតែមានសិទ្ធនិងកាតព្វកិច្ចរៀងៗខ្លួន ក្នុងការធ្វើការប្តឹងទាស់ទៅនឹងសេចក្តីសម្រេចណាមួយរបស់តុលាការ មិនថាដោយចំណុចណាមួយ ឬចំណុចទាំងអស់នៃការសម្រេចរបស់តុលាការនោះទេ។ ប៉ុន្តែត្រូវដំណើរការទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់ ទៅតាម ទម្រង់ រយៈពេល ទៅតាមដំណាក់កាលនៃតុលាការនីមួយៗប្រព្រឹត្តទៅដោយ តុល្យភាព និងកាន់តែមានសុក្រិតភាពក្នុងការស្វែងរកយុត្តិធម៌។ ភាគីម្នាក់ៗអាចយកសិទ្ធដែលខ្លួនមានមកប្រើប្រាស់ជាសំអាងនៅពេលដែលមានការរំលោភបំពានសិទ្ធ របស់ខ្លួនដោយភាគីដទៃទៀត ឬដោយអាជ្ញាធរតុលាការ។ តាមរយៈការប្តឹងទាស់ គឺ ភាគីម្នាក់ៗអាចយកសិទ្ធដែលខ្លួនមានទៅប្រើប្រាស់ដើម្បីតទល់ទៅនឹងចំណាត់ការនីតិវិធីនិងការសម្រេចសេចក្តីដោយរំលោភបំពានដោយភាគីណាមួយផ្សេងទៀតនៃរឿងក្តី។

បណ្ដឹងទាស់ទៅនឹងសាលក្រមចំពោះមុខ តុលាការជាន់ដំបូង តាមរយៈការប្ដឹងឧទ្ធរណ៍តាំងតែពី ដំណាក់កាលដំបូង មុននឹងធ្វើការប្ដឹងទាស់នឹងសាលក្រមកំបាំងមុខ និងការប្ដឹងទាស់នឹង សាលក្រមចំពោះមុខតុលាការ រាជធានីខេត្តតាមរយៈការប្ដឹងឧទ្ធរណ៍ រហូតដល់ការ សម្រេច សេចក្ដីចុងក្រោយ របស់តុលាការតាមរយៈ សាលក្រម ឬសាលដីកាដែលសម្រេចលើបណ្ដឹង ទាស់នោះ។ មុននឹងឈានដល់ការចេញនូវ សាលក្រម ឬសាលដីកានីមួយៗ ត្រូវឆ្លងកាត់នូវលក្ខខណ្ឌជាច្រើនដូចជា ការកំណត់បុគ្គលដែលមានសិទ្ធក្នុងការប្ដឹងទាស់ រយៈពេលទម្រង់ ទីកន្លែង នៃការធ្វើបណ្ដឹងទាស់ មិនថាបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ឬបណ្ដឹងទាស់ចំពោះសាលក្រមចំពោះមុខនោះទេ ត្រូវឆ្លងកាត់នូវដំណាក់កាល ទាំងអស់នេះដូចគ្នា។ ជាងនេះទៅទៀតនោះក្នុងសារណានេះ ក៏បានរៀបរាប់យ៉ាងច្បាស់អំពីអានុភាពនៃបណ្ដឹងទាស់ អនុភាពនៃសាលក្រមដែលសម្រេចលើបណ្ដឹងទាស់ ព្រមទាំងផ្ដល់សិទ្ធក្នុងការទាស់នេះទៀតផង។

ស្របជាមួយនឹងចំណុចវិជ្ជមានខាងលើ យើងក៏ឃើញមាននូវចំណុចអវិជ្ជមានជាច្រើនដែលមួយផ្នែកជាបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងមួយផ្នែកទៀតជាផលអវិជ្ជមានដែលបានមកពីការអនុវត្ត តែទោះបីជាយ៉ាងណាក៏ដោយដើម្បីឆ្លើយតបនឹងបញ្ហាទាំងអស់នេះ គណកម្មាការទទួលបន្ទុកតាក់តែងក្រមនីតិវិធីព្រហ្មទណ្ឌ បានមើលឃើញជាមុននូវករណីអសកម្មទាំងនេះ ហើយបានដាក់ជាវិធានផ្សេងៗនៅគ្រប់ដំណាក់កាលនីតិវិធីជាដំណោះស្រាយចំពោះគុណវិបត្តិទាំងនេះ។
វិធានដែលបានពោលខាងលើគឺសំដៅយកការអនុវត្តនូវសិទ្ធប្ដឹងតវ៉ា ផ្សេងៗរបស់ភាគីនីមួយៗ។ ថ្វីត្បិតតែលិខិតបទដ្ឋានគតិយុត្តិពុំទាស់បានចែងអោយច្បាស់លាស់ តែថ្នាក់ដឹកនាំរបស់ស្ថាប័នតុលាការបានខិតខំបង្កើតនូវសេចក្ដីសម្រេចនានា ដើម្បីបំពេញចំណុចខ្វះខាតចន្លោះរបស់ច្បាប់ និងជួយសម្រួលដល់ការអនុវត្តនីតិវិធីឱ្យកាន់តែមានភាពល្អប្រសើរ និងឆាប់រហ័ស។

ជារួមមកយើងឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងលម្អិត នៅគ្រប់ដំណាក់កាល នៃការប្ដឹងទាស់ មិនថាការប្ដឹងទាស់នៅដំណាក់កាលតុលាការជាន់ដំបូង ឬនៅដំណាក់កាលនៃ តុលាការជាន់ខ្ពស់នោះទេមានលក្ខណៈល្អប្រសើរ និងមានការអនុគ្រោះដល់គ្រប់ភាគីមានពេលវេលាច្រើនក្នុងការប្ដឹងទាស់។
លើសពីនេះទៅទៀតក្រមបានផ្ដល់សិទ្ធ និងកាតព្វកិច្ចដល់គ្រប់ភាគីក្នុងការចូលរួមគ្រប់នីវិធីដែលភាគីអាចប្រើប្រាស់សិទ្ធនោះដើម្បីជាប្រយោជន៍របស់ខ្លួន តាមរយៈការតតាំងទៅនឹងចំណាត់ការទាំងឡាយរបស់អាជ្ញាធរតុលាការ។

តាមរយៈការលើកឡើងខាងលើ យើងឃើញថាតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា បច្ចុប្បន្ននេះវាពិតជាសមស្របបំផុតដែលត្រូវអនុវត្តនីតិវិធីព្រហ្មទណ្ឌតាមក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ យើងនេះ។ បញ្ហាតែមួយគត់ដែលយើងមានការប្រឈមគឺ ទាក់ទងទៅនឹងកម្រិតនៃការយល់ដឹងផ្នែកច្បាប់របស់បុគ្គលគ្រប់រូបឱ្យបានដឹងថានៅពេលមានការប្រឈមមុខនឹងរឿងក្តីព្រហ្មទណ្ឌ តើនឹងមានការប្រើប្រាស់សិទ្ធបានច្រើនប៉ុណ្ណា ហើយការប្រើប្រាស់សិទ្ធនោះមានប្រសិទ្ធភាពយ៉ាងណា? ម្យ៉ាងទៀត ថាតើអាជ្ញាធរដែលមានសមត្ថកិច្ចបានអនុវត្តទៅតាមបញ្ញត្តិច្បាប់ត្រឹមត្រូវក្នុងកម្រិតមួយដែលអាចទទួលយកបានប៉ុណ្ណា។

នាងខ្ញុំសង្ឃឹមថា សារណានេះ អាចជួយដល់ការសិក្សាផ្នែកនីតិសាស្ត្រអោយយល់ច្បាស់អំពីការអនុវត្តនីតិវិធីជាក់ស្តែងនៅពេលមានបណ្តឹងទាស់ មិនថាបណ្តឹងទាស់នៅតុលាការជាន់ដំបូង ឬបណ្តឹងទាស់នៅសាលាឧទ្ធរណ៍។ ម្យ៉ាងវិញទៀត នាងខ្ញុំយល់ឃើញថាការរៀបរៀងសារណានេះ ប្រាកដជាបានចូលរួមចំណែកដល់និស្សិត និងប្រជាពលរដ្ឋ គ្រប់ស្រទាប់ជាន់ថ្នាក់ពិសេសមន្រ្តីអនុវត្ត ដែលចង់ស្វែងយល់បន្ថែមផ្នែកច្បាប់និងនីតិវិធីនៅពេលមានបណ្តឹងទាស់។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវអំពីបណ្តឹងទាស់រួចមកធ្វើឱ្យនាងខ្ញុំ បានសង្កេតឃើញនូវ ចំណុចខ្វះខាតមួយចំនួនលើការ អនុវត្តជាក់ស្តែងដើម្បីចូលរួមចំណែកដល់ការអនុវត្តឱ្យកាន់តែល្អប្រសើរនាងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដូច ខាងក្រោមៈ

- សូមឱ្យអង្គនីតិបញ្ញត្តិ អនុម័តច្បាប់ក្នុងវិស័យតុលាការឱ្យកាន់តែច្បាស់លាស់
- សូមឱ្យរាជរដ្ឋាភិបាលជួយពង្រឹងប្រព័ន្ធតុលាការ
- សូមឱ្យក្រសួងយុត្តិធម៌ ក៏ដូចជាក្រសួងពាក់ព័ន្ធ មេត្តាបន្តការផ្សព្វផ្សាយច្បាប់ឱ្យមានភាពទូលំទូលាយ ដល់មន្ត្រីអនុវត្ត និងប្រជាពលរដ្ឋគ្រប់ស្រទាប់ឱ្យយល់រិតតែច្បាស់បន្ថែមទៀត
- សូមឱ្យក្រសួងយុត្តិធម៌បង្កើតតុលាការជាន់ខ្ពស់ឱ្យមានគ្រប់កន្លែង
- សូមឱ្យក្រសួងអប់រំយុវជន និងកីឡា រួមទាំងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់គួរតែបញ្ចូលកម្មវិធីសិក្សាអំពីមុខវិជ្ជាច្បាប់ឱ្យកាន់តែច្រើន និងផ្តល់អាទិភាពដល់សិស្ស និស្សិតអាចមានពេលចុះកម្មសិក្សានៅស្ថាប័នតុលាការ
- សូមសំណូមពរដល់មន្ត្រីអនុវត្តច្បាប់ទាំងអស់ ពង្រឹងសមត្ថភាព និងស្វែងយល់អំពីតួនាទីរបស់ខ្លួន ដើម្បីឱ្យការអនុវត្តច្បាប់មានភាពយុត្តិធម៌ និងជៀសវាងមានកំហុសក្នុងពេលអនុវត្តច្បាប់
- សូមសំណូមពរដល់ប្រជាពលរដ្ឋទាំងអស់ ព្យាយាមស្វែងយល់នូវវិស័យច្បាប់ឱ្យកាន់តែមានភាពច្បាស់លាស់ ស្របតាមការណែនាំ និងផ្សព្វផ្សាយរបស់អាជ្ញាធរដើម្បីជៀសវាងការប្រព្រឹត្តបទល្មើសណាមួយជាយថាហេតុ។
- សូមសំណូមពរដល់សិស្ស និស្សិតគ្រប់ជាន់ថ្នាក់ ដែលមានសមត្ថភាពផ្នែកច្បាប់ពង្រឹងបន្ថែមនូវសមត្ថភាពរបស់ខ្លួនឱ្យកាន់តែខ្ពស់ ដើម្បីជួយដល់ការអនុវត្តច្បាប់របស់ប្រទេសកម្ពុជាយើងឱ្យក្លាយទៅជា នីតិរដ្ឋពេញលេញ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:........................
ចុះថ្ងៃទី.......................

**សាលក្រម**
លេខ:........................
ចុះថ្ងៃទី.......................

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូង ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលជម្រះក្តីជាន់ដំបូង កាលថ្ងៃទី............. ខែ..............ឆ្នាំ............... ដែលមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

.......................................................ប្រធាន

....................................ចៅក្រមប្រឹក្សា

....................................ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

.......................................................

**ក្រឡាបញ្ជី**

.......................................................

ដើម្បីជំនុំជំរះលើជនជាប់ចោទ នៃសំណុំរឿងព្រហ្មទណ្ឌលេខ......................... រវាង ៖

ជនជាប់ចោទឈ្មោះ.................................. ភេទ............អាយុ...................ឆ្នាំ មុខរបរ...................................ជាតិ........................... កើតនៅ.................................................
..........................................................................................................................................................................

ឪពុកឈ្មោះ.................................(..............) ម្តាយឈ្មោះ.................................(................) ។

ប្រពន្ធ ឬប្តីឈ្មោះ............................. ។ ទោសពីមុន មាន ឬ គ្មាន ។

ត្រូវចោទពីបទ: ..............................................................................................

ប្រព្រឹត្តនៅ....................................................................................................................

...............................................................កាលពីថ្ងៃទី............ខែ.....................ឆ្នាំ..............................

បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា...........................នៃ......................................

...................................................។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ.................................................... ភេទ............

អាយុ...............ឆ្នាំ មុខរបរ....................................ជាតិ........... ទីនៅបច្ចុប្បន្ន..........................

...........................................................................................................................

........................................................................................................។

**ការប្រព្រឹត្ត នៅរបស់ជនជាប់ចោទ៖**

....................................................................................................

...........................................................................................................................

...........................................................................................................................

...................................................................................................................... ។

**បានឃើញ ដីការសន្និដ្ឋានស្ថាពរលេខ** ......................ចុះថ្ងៃទី...............

ខែ.................ឆ្នាំ...............របស់សាលាដំបូង...............................បានសំរេចសេចក្តីដូចតទៅ ៖

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...................................................................................................................... ។

**បានឃើញដីការបញ្ជូន រឿងទៅជំនុំជម្រះ លេខ**...........................

ចុះថ្ងៃទី..................ខែ.................. ឆ្នាំ...............របស់សាលាដំបូង................................. ។

**បានឃើញដីការចាត់តាំងចៅក្រមជំនុំជម្រះ លេខ**.........................

ចុះថ្ងៃទី..................ខែ.................. ឆ្នាំ...............របស់សាលាដំបូង................................. ។ .

**នាពេលសវនាការ**

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................។

## សភាព្រហ្មទណ្ឌ យល់ឃើញថា

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា............ | ហត្ថលេខា............,............ | ហត្ថលេខា............ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង**..........................

លេខ....................ចុះថ្ងៃទី..............

ខែ.........................ឆ្នាំ..................

សំណុំរឿងព្រហ្មទណ្ឌលេខ:..............

ចុះថ្ងៃទី.............................

# បណ្តឹងទាស់

ឆ្នាំ............................ខែ........................ ថ្ងៃទី...........................

វេលាម៉ោង....................................................................... ។

យើង.....................................................ក្រឡាបញ្ជីសាលាឧទ្ធរណ៍ ។

បានឃើញឈ្មោះ.................................................. ចូលមកចំពោះមុខ
យើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូង .................................... ហើយសុំប្តឹងទាស់
នឹងសាលក្រមលេខ.....................ចុះថ្ងៃទី....................ខែ........................ឆ្នាំ..................
ត្រង់ចំណុច..................................................................................................
.........................................................................................................................
.........................................................................................................................
.........................................................................................................................
....................................................................................................................... ។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ.........................................
ស្តាប់ហើយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

| | |
|---|---|
| **អ្នកប្តឹង** | **ក្រឡាបញ្ជី** |
| ស្នាមមេដៃស្តាំ | ហត្ថលេខា |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**...............................
លេខ:.........................................

# ដីកាបញ្ជូន

**ផ្ញើជូន:**..........................................................................................

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| | | | |
| | សរុប | | |

.................., ថ្ងៃទី............ខែ.....................ឆ្នាំ ២០១៤

**ប្រធាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង**.........................

លេខ.......................ចុះថ្ងៃទី..............
ខែ...........................ឆ្នាំ.....................
សំណុំរឿងព្រហ្មទណ្ឌលេខ:................
ចុះថ្ងៃទី.......................................

# បណ្តឹងឧទ្ធរណ៍

ឆ្នាំ....................................ខែ............................ ថ្ងៃទី...............................
វេលាម៉ោង...............................................................។
យើង......................................ក្រឡាបញ្ជីសាលាដំបូង..........................។
បានឃើញឈ្មោះ.................................................... ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូង.................................. ហើយសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ.........................ចុះថ្ងៃទី........................ខែ...........................ឆ្នាំ.........................
ត្រង់ចំណុច.............................................................................................................
.............................................................................................................................
.............................................................................................................................
.............................................................................................................................
.......................................................................................................................... ។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ........................................... ស្តាប់ហើយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

**អ្នកប្តឹង** **ក្រឡាបញ្ជី**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងឧទ្ធរណ៍

យើងខ្ញុំទាំងអស់គ្នាមានឈ្មោះដូចខាងក្រោមៈ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ ..............................

..............................................................................................................................................................................

## សូមគោរពចូលមក

## លោកប្រធានសាលាដំបូង

**កម្មវត្ថុ** : សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ.....................ចុះថ្ងៃទី.......ខែ....... ឆ្នាំ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ........................... មេត្តាជួយទទួលចាត់ការតាមច្បាប់ដោយសេចក្តីអនុគ្រោះ។

សូម........................... មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃទី.......ខែ....... ឆ្នាំ.......

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ:........ ...................... ...........

ចុះថ្ងៃទី.........ខែ.........ឆ្នាំ..........

សំណុំរឿងព្រហ្មទណ្ឌ

លេខ:.................................................

ចុះថ្ងៃទី.........ខែ..........ឆ្នាំ.........

របស់សាលាដំបូង..................

**សេចក្តីប្តឹងឧទ្ធរណ៍**

ឆ្នាំពីរពាន់.................ខែ.......................ថ្ងៃ.......................

វេលាម៉ោង.......................................................................

យើង.............................................អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាល

សាលាឧទ្ធរណ៍ភ្នំពេញ។

បានឃើញឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

ចូលមកចំពោះមុខយើង ដែលប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ....................
ចុះថ្ងៃទី.............ខែ...............ឆ្នាំ.................របស់សាលាដំបូង ...................................

ត្រង់ចំណុច.នៃសេចក្តីសម្រេចក្នុងសាលក្រម ។

អគ្គព្រះរាជអាជ្ញា

អគ្គលេខាធិការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

♦♦♦♦♦♦

សាលាដំបូងខេត្តតាកែវ

លេខ..........ចុះថ្ងៃទី......................

សុំណុំរឿងលេខ......................

ចុះថ្ងៃទី.........ខែ.........ឆ្នាំ...............

# សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍

♦♦♦♦♦♦

ឆ្នាំពីរពាន់.............................................ថ្ងៃទី....................វេលាម៉ោង.......................

យើង...............................................ក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ ។

បានឃើញ ............................................................ ចូលមកចំពោះមុខយើង នៅការិយាល័យ

ក្រឡាបញ្ជីនៃសាលាដំបូង...............ហើយសុំប្ដឹងឧទ្ធរណ៍នឹង. ...................................................

........................................................លេខ............. ចុះថ្ងៃទី............ខែ............ឆ្នាំ............

ត្រង់ចំនុច ..........................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្ដីនេះឱ្យឈ្មោះ..........................................................ស្ដា

ហើយឱ្យចុះហត្ថលេខា ឬផ្ដិតមេដៃជាមួយយើង ។

**អ្នកប្ដឹង**

ស្នាមមេដៃ ឬ ហត្ថលេខា

**ក្រឡាបញ្ជី**

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:..........................
ចុះថ្ងៃទី.......................

**សាលដីកា**
លេខ:.......................
ចុះថ្ងៃទី.......................

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ០៦ក្រចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ កាលថ្ងៃទី............ ខែ..............ឆ្នាំ............... ដែលមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

......................................................**ប្រធាន**

.......................................**ចៅក្រមប្រឹក្សា**

.......................................**ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

.................................................................

**ក្រឡាបញ្ជី**

...............................................................

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ........................... រវាង ៖

ជនជាប់ចោទឈ្មោះ.................................... ភេទ............អាយុ...................ឆ្នាំ មុខរបរ.....................................ជាតិ........................... កើតនៅ.........................................................
.................................................................................................................................................

ឪពុកឈ្មោះ...................................(...............) ម្តាយឈ្មោះ....................................(................) ។

ប្រពន្ធ ឬប្តីឈ្មោះ............................ ។ ទោសពីមុន មាន ឬ គ្មាន ។

ត្រូវចោទពីបទ: ........................................................................................

ប្រព្រឹត្តនៅ..................................................................................................

......................................................កាលពីថ្ងៃទី............ខែ...................ឆ្នាំ.....................

បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា............................នៃ.............................

............................................... ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ.................................................... ភេទ............

អាយុ..............ឆ្នាំ មុខរបរ..................................ជាតិ............ ទីនៅបច្ចុប្បន្ន..........................

...........................................................................................................................

............................................................................................................... ។

**ឯដំណើររឿងមានដូចតទៅ ៖**

.......................................................................................................

...........................................................................................................................

...........................................................................................................................

........................................................................................................................... ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ...............................ចុះថ្ងៃទី...............

ខែ................ឆ្នាំ...............របស់សាលាដំបូង..............................បានសំរេចសេចក្តីដូចតទៅ ៖

...........................................................................................................................

...........................................................................................................................

...........................................................................................................................

.................................................................................................... ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃ............................របស់.....................

មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ.............................ចុះថ្ងៃទី.................ខែ..................

ឆ្នាំ..............របស់សាលាដំបូង...................................គ្រង់ចំណុច..................................

...........................................................................................................................

.................................................................................................... ។

**បានឃើញ** របាយការណ៍របស់សាលាឧទ្ធរណ៍ ។

**បានឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................។

## សភាព្រហ្មទណ្ឌ យល់ឃើញថា

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ដំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា............ | ហត្ថលេខា............,............ | ហត្ថលេខា............ |

---

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី......... ខែ.............. ឆ្នាំ..............

**បានឃើញ** **ក្រឡាបញ្ជី**

**ប្រធានសាលាឧទ្ធរណ៍**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

លេខ........................ចុះថ្ងៃទី..............
ខែ............................ឆ្នាំ......................
សំណុំរឿងព្រហ្មទណ្ឌលេខ:...............
ចុះថ្ងៃទី..........................................

# បណ្តឹងទាស់

ឆ្នាំ..................................ខែ............................ ថ្ងៃទី.................................
វេលាម៉ោង.........................................................................។
យើង.....................................................ក្រឡាបញ្ជីសាលាឧទ្ធរណ៍ ។
បានឃើញឈ្មោះ................................................... ចូលមកចំពោះមុខ
យើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍......................................... ហើយសុំប្តឹងទាស់
នឹងសាលដីកាលេខ.........................ចុះថ្ងៃទី.......................ខែ............................ឆ្នាំ..................
ត្រង់ចំណុច.............................................................................................................................
...............................................................................................................................................
...............................................................................................................................................
...............................................................................................................................................
........................................................................................................................................ ។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ................................................
ស្តាប់ហើយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

| **អ្នកប្តឹង** | **ក្រឡាបញ្ជី** |
|---|---|
| ស្នាមមេដៃស្តាំ | ហត្ថលេខា |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

លេខ.........................ចុះថ្ងៃទី...............

ខែ..............................ឆ្នាំ......................

សំណុំរឿងព្រហ្មទណ្ឌលេខ:................

ចុះថ្ងៃទី.........................................

# បណ្តឹងសាទុក្ខ

ឆ្នាំ.................................ខែ.............................. ថ្ងៃទី................................

វេលាម៉ោង.....................................................................។

យើង.........................................................ក្រឡាបញ្ជីសាលាឧទ្ធរណ៍ ។

បានឃើញឈ្មោះ................................................... ចូលមកចំពោះមុខ
យើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍........................................ ហើយសុំប្តឹងសាទុក្ខ
នឹងសាលដីកាលេខ..........................ចុះថ្ងៃទី........................ខែ...........................ឆ្នាំ
.........................

ត្រង់ចំណុច...........................................................................................................
..........................................................................................................................
..........................................................................................................................
..........................................................................................................................
.......................................................................................................................។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ.............................................
ស្តាប់ហើយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

| **អ្នកប្តឹង** | **ក្រឡាបញ្ជី** |
|---|---|
| ស្នាមមេដៃស្តាំ | ហត្ថលេខា |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ:..............................................

## ដីកាបញ្ជូន

**ផ្ញើជូន:**..............................................................................................

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| | | | |
| | សរុប | | |

........................, ថ្ងៃទី..............ខែ.........................ឆ្នាំ ២០១៥

**ប្រធាន**